# 6 ការការពារទឹកក្នុងសហគមន៍

**នៅក្នុងជំពូកនេះ :** **ទំព័រ**


មនុស្សគ្រប់គ្នាត្រូវការទឹក . . . 66
សាច់រឿង : ឧស្សាហកម្មយកទឹករបស់សហគមន៍ . . . 67
បង្កើនការយល់ដឹងក្នុងសហគមន៍ . . . 68
តើទឹករបស់អ្នកមានសុវត្ថិភាពឬទេ? . . . 69
សកម្មភាព : ទឹកថ្លាអាចមិនមែនជាទឹកស្អាត . . . 69
កែលម្អប្រភពទឹករបស់អ្នក . . . 70
ស្ត្រីជាមនុស្សសំខាន់ក្នុងការរៀបចំផែនការ . . . 72
សកម្មភាព : រង្វង់២ . . . 72
សាច់រឿង : រលំាងរាំងការកែលម្អប្រភពទឹករបស់អ្នក . . . 73
ការពារប្រភពទឹក . . . 75
អណ្តូងដែលបានការពារ . . . 76
ជំហានដើម្បីធ្វើឲ្យអណ្តូងស្នប់ និងអណ្តូងជីក មានសុវត្ថិភាព . . . 77
ការពារអណ្តូងប្រចាំគ្រួសារ . . . 79
ការបូមទឹកពីអណ្តូង . . . 83
ការពារកន្លែងទឹកចេញ . . . 84
ត្រងទឹកភ្លៀង . . . 86
សាច់រឿង : ការប្រមូលទឹកភ្លៀងនៅក្នុងតំបន់វាលខ្សាច់ . . . 87
ការជញ្ជូនទឹកសុវត្ថិភាព . . . 88
សាច់រឿង : បុរសនិងស្ត្រីនិយាយអំពីទឹក . . . 89
ស្តុកទឹកទុកដោយសុវត្ថិភាព . . . 90
សកម្មភាព : តើទឹកផឹកត្រូវបានធ្វើឲ្យកខ្វក់ដោយរបៀបណា? . . . 90
ធ្វើទឹកឲ្យមានសុវត្ថិភាពសម្រាប់ផឹក . . . 92
ការទុកទឹកឲ្យរង . . . 93
ការច្រោះទឹក . . . 94
ការរម្ងាប់មេរោគក្នុងទឹក . . . 97
ទឹកសំណល់ : ជាបញ្ហា ឬជាធនធាន? . . . 100

# ការការពារទឹកក្នុងសហគមន៍



ទឹកមានសារសំខាន់ចំពោះជីវិត។ មនុស្ស សត្វ និងរុក្ខជាតិ សុទ្ធតែត្រូវការទឹកដើម្បីរស់នៅនិងលូតលាស់។ ប៉ុន្តែនៅតំបន់ជាច្រើន មនុស្សគ្មានទឹកគ្រប់គ្រាន់ដើម្បីឲ្យមានសុខភាពល្អទេ។ មានមនុស្សជាច្រើនត្រូវធ្វើដំណើរយ៉ាងឆ្ងាយដើម្បីទៅដងទឹក។ ហើយជាញឹកញាប់ ទឹកដែលមានហើយគឺមិនអាចផឹកបានដោយសុវត្ថិភាពទេ។

នៅពេលសហគមន៍មួយមានប្រភពទឹកដែលមានសុវត្ថិភាព និងងាយទៅយក នោះប្រជាជនគ្រប់គ្នាមានឱកាសច្រើនក្នុងការទទួលបានសុខភាពល្អ។ ប្រសិនបើស្ត្រីនិងក្មេងស្រីមិនចាំបាច់ទៅដងទឹកនិងបន្សុទ្ធវារាល់ថ្ងៃទេ នោះពួកគេនឹងមានពេលវេលាបន្ថែមដែលអាចទៅសាលារៀន និងធ្វើជាផ្នែកដ៏សំខាន់មួយក្នុងសហគមន៍។ បែបនេះនឹងកែលម្អសុខុមាលភាពមនុស្សគ្រប់គ្នា។ ដោយមានទឹកស្អាតគ្រប់គ្រាន់ កុមារលូតលាស់បានល្អ និងមិនសូវកើតជំងឺរាកដែលបង្កឡើងដោយទឹកមិនស្អាត។

# ទឹក និងសុខភាពសហគមន៍

ទឹកគឺជាអំណោយពីធម្មជាតិ។ ហើយ**សន្តិសុខទឹក**( លទ្ធភាពទទួលបានទឹកស្អាតគ្រប់គ្រាន់ជាប្រចាំ ) គឺជាផ្នែកមួយដ៏សំខាន់នៃសុខភាពសហគមន៍។ នៅពេលប្រជាជនធ្វើការសម្រេចចិត្តជាមួយគ្នាអំពីវិធីប្រមូលទឹក ស្តុកទឹក និងប្រើប្រាស់ប្រភពទឹករួមគ្នា នោះពួកគេអាចធានាបាននូវសន្តិសុខទឹកក្នុងសហគមន៍។

ដើម្បីឲ្យបានទឹកស្អាតគ្រប់គ្រាន់ មនុស្សស្ទើរតែគ្រប់គ្នាសុខចិត្តធ្វើការងារដែលចាំបាច់ ឬបង់ប្រាក់ក្នុងតម្លៃមួយដែលសមរម្យ។ ប៉ុន្តែនៅតំបន់ជាច្រើន ទឹកដែលប្រជាជនត្រូវការយកមកផឹក ត្រូវបានឆ្លងដោយមេរោគ ដង្កូវ ឬសារធាតុគីមីពុល, ត្រូវឧស្សាហកម្មឬកសិកម្មទំនើបយកមុន, ឬត្រូវបានលក់ក្នុងតម្លៃមួយដែលប្រជាជនគ្មានលទ្ធភាពទិញ។ នៅពេលសម្រេចចិត្តអំពីតម្លៃរបស់ទឹក និងអំពីវិធីការពារ ស្តុក ចែកចាយ និងប្រើប្រាស់ទឹក, គួរគិតថាតម្រូវការទឹករបស់ប្រជាជនដើម្បីរស់រាននិងមានសុខភាពល្អ មានសារសំខាន់ជាងតម្រូវការដទៃៗទៀតទាំងអស់។



## មនុស្សគ្រប់គ្នាត្រូវការទឹក





## ឧស្សាហកម្មយកទឹករបស់សហគមន៍



ផ្លាជីម៉ាដា គឺជាភូមិតូចមួយនៅក្នុងប្រទេសឥណ្ឌាភាគខាងត្បូង ជាទីកន្លែងដែលកសិករដាំដុះស្រូវនិងផ្លែដូង។ កសិករធ្លាប់មានជីវភាពរស់នៅល្អ ព្រោះនៅទីនោះធ្លាប់មានទឹកភ្លៀងច្រើននិងដីមានជីជាតិ។ ប៉ុន្តែពីរបីឆ្នាំមុន ភូមិនេះបានចាប់ផ្តើមផ្លាស់ប្តូរ បន្ទាប់ពីក្រុមហ៊ុនកូកាកូឡាសាងសង់រោងចក្រនៅជាយភូមិ។

រោងចក្របានជីកអណ្តូងជ្រៅៗជាច្រើនដើម្បីយកទឹកក្រោមដីផលិតជាភេសជ្ជៈផ្អែម។ រោងចក្របានប្រើប្រាស់ទឹកប្រមាណ១,៥លានលីត្រជារៀងរាល់ថ្ងៃ។ ពីរឆ្នាំបន្ទាប់ពីរោងចក្រដំណើរការ ដំណាំរបស់ប្រជាជនបានចាប់ផ្តើមងាប់ ហើយអណ្តូងទឹកតាមផ្ទះក៏រីងស្ងួតជាបណ្តើរៗ។ នៅពេលពួកគេចម្អិនបាយ វាប្រែជាពណ៌ខ្មោតនិងមានរសជាតិមិនល្អ។ នៅពេលពួកគេផឹកទឹកឬងូតទឹក ពួកគេមានកន្ទួលលើស្បែក ជ្រុះសក់ ឈឺសន្លាក់ ឆ្អឹងខ្សោយ និងបញ្ហាសរសៃប្រសាទ។ ពួកគេដឹងថាក្រុមហ៊ុនបានធ្វើឲ្យពុលដល់ទឹកក្នុងដីដោយសារធាតុគីមីពុល។ ដើម្បីការពារសុខភាព អ្នកភូមិចាប់ផ្តើមទៅយកទឹកនៅឆ្ងាយៗពីផ្ទះ។

ក្នុងរយៈពេល១ឆ្នាំ ភ្លៀងមិនធ្លាក់ទាល់តែសោះ។ ប៉ុន្តែក្រុមហ៊ុនកូកាកូឡានៅតែបន្តយកទឹកក្នុងពេលរាំងស្ងួត។ រាល់ថ្ងៃអ្នកភូមិសំឡឹងមើលរថយន្តបើកចេញពីរោងចក្រដោយដឹកយកទៅនូវទឹកដ៏មានតម្លៃដែលធ្លាប់ផ្តល់ជីវិតដល់ពួកគេនិងដំណាំរបស់ពួកគេ។ សូម្បីតែប្រភពទឹកដែលនៅឆ្ងាយពីភូមិក៏រីងស្ងួតដែរ។ នៅពេលប្រជាជនកាន់តែច្រើនចាប់ផ្តើមឈឺ ពួកគេបានជួបជុំគ្នារិះរកវិធីដើម្បីឲ្យរោងចក្រកូកាកូឡាឈប់យកទឹករបស់ខ្លួនទៀត។

បន្ទាប់ពីការជួបជុំគ្នា អ្នកប្រឆាំងតវ៉ាដោយសន្តិភាពជាង២.០០០នាក់ បានដើរដង្ហែរក្បួនទៅកាន់រោងចក្រកូកាកូឡា ហើយទាមទារឲ្យក្រុមហ៊ុនចាកចេញ និងបង់ប្រាក់សំណងជូនអ្នកភូមិដែលបានបាត់បង់ទឹក។ រោងចក្របានឆ្លើយតបវិញដោយបានបញ្ជូនរថយន្តដឹកទឹកពេញទៅឲ្យអ្នកភូមិរៀងរាល់ថ្ងៃ។ ប៉ុន្តែទឹកនេះមិនគ្រប់គ្រាន់នឹងបំពេញតម្រូវការរបស់អ្នកភូមិទេ។ បន្ទាប់ពីការតវ៉ារយៈពេល៥០ថ្ងៃ ប៉ូលីសបានចាប់ខ្លួនពួកគេចំនួន១៣០នាក់។ ច្រើនខែក្រោយមកទៀត អ្នកភូមិប្រមាណ១.០០០នាក់បានដើរដង្ហែរក្បួនទៅរោងចក្រម្តងទៀត ហើយប៉ូលីសបានចាប់ខ្លួនពួកគេជាច្រើននាក់ទៀត។

ការតស៊ូបានធ្វើឲ្យអ្នកភូមិផ្លាជីម៉ាដាលំបាកវេទនា ប៉ុន្តែវាក៏បានធ្វើឲ្យពួកគេរួបរួមគ្នាដើម្បីទាមទារការគោរពសិទ្ធិក្នុងការទទួលបានទឹកស្អាតដែរ។ ច្រើនឆ្នាំក្រោយមក អាជ្ញាធរស្រុកបានចាប់ផ្តើមគាំទ្រប្រជាជន ហើយបញ្ជាឲ្យក្រុមហ៊ុនបញ្ឈប់ការប្រើប្រាស់ទឹកក្រោមដីក្នុងពេលរីងស្ងួត។ ប៉ុន្តែអាជ្ញាធរខេត្តនិយាយថា គួរតែអនុញ្ញាតឲ្យក្រុមហ៊ុនបន្តប្រើប្រាស់ទឹកក្រោមដី។ ជម្លោះនេះបានឡើងដល់តុលាការ ដែលទីបញ្ចប់អ្នកភូមិផ្លាជីម៉ាដាបានឈ្នះក្តី ហើយក្រុមហ៊ុនកូកាកូឡាត្រូវបានបិទទ្វារ។

នៅពេលអ្នកភូមិផ្លាជីម៉ាដាប្រយុទ្ធទាមទារសិទ្ធិក្នុងការប្រើប្រាស់ទឹក យុទ្ធនាការរបស់ពួកគេបានទាញចំណាប់អារម្មណ៍ពីប្រជាជននៅទូទាំងប្រទេសឥណ្ឌានិងពិភពលោក។ ការតស៊ូរបស់ពួកគេបានផ្តល់កម្លាំងចិត្តដល់មនុស្សជាច្រើន។ ក្នុងពិភពលោកដែលប្រជាជនមិនមានទឹកស្អាតគ្រប់គ្រាន់ ការប្រើប្រាស់ធនធានដ៏មានកម្រិតមួយនេះដើម្បីយកទៅធ្វើជាភេសជ្ជៈប្រណិតៗ គឺជាការមិនសមហេតុផលសោះ ជាពិសេសបើការប្រើប្រាស់ទឹករបស់រោងចក្រ ធ្វើឲ្យប្រជាជនមានជំងឺ។

# បង្កើនការយល់ដឹងក្នុងសហគមន៍

ស្ត្រីម្នាក់ដែលដងទឹកពីកន្លែងឆ្ងាយៗរៀងរាល់ថ្ងៃ ដឹងយ៉ាងច្បាស់ថាវាជាការងារធ្ងន់ធ្ងរ។ ប៉ុន្តែគាត់ប្រហែលជាមិនដឹងខ្លួនថាគាត់មានអំណាចក្នុងការផ្លាស់ប្តូរវាទេ។

នៅពេលប្រជាជនមើលឃើញថា តម្រូវការទឹកដែលស្អាតនិងដែលទុកចិត្តបាន គឺជាបញ្ហារបស់មនុស្សគ្រប់គ្នា នោះពួកគេអាចចាប់ផ្តើមធ្វើការជាមួយគ្នាដើម្បីការផ្លាស់ប្តូរ។ ការបង្កើនការយល់ដឹងក្នុងសហគមន៍ គឺជាដំណាក់កាលដំបូងនៃការផ្លាស់ប្តូរ ហើយជាទូទៅវាត្រូវការមនុស្សជាច្រើនក្រុមមកធ្វើការរួមគ្នាដើម្បីឈានទៅមុខបាន។



### ជជែកជាមួយអ្នកទទួលបន្ទុកផ្នែកទឹក

តើមាននរណា ក្រុមណា ឬក្រុមហ៊ុនណាដែលទទួលខុសត្រូវលើអណ្តូង ប្រព័ន្ធទឹកស្អាត ឬប្រព័ន្ធផ្គត់ផ្គង់ទឹកដទៃទៀតដែរឬទេ? តើមានមនុស្សឬក្រុមណាមួយដែលទទួលខុសត្រូវលើផ្នែកអនាម័យឬទេ? តើនរណាខ្លះឬក្រុមណាខ្លះដែលដងទឹក រែកទឹក បន្សុទ្ធ និងស្តុកទុកទឹកញឹកញាប់ជាងគេ?

ជាមួយអ្នកទទួលខុសត្រូវផ្នែកទឹក ចូររៀបរាប់ពីប្រភពទឹកទាំងអស់ដែលមានក្នុងតំបន់។ តើប្រជាជននិយាយដូចម្តេចខ្លះអំពីគុណភាពនិងបរិមាណទឹកផឹក? តើទឹកត្រូវបានប្រើប្រាស់ក្នុងមួយថ្ងៃអស់ប៉ុន្មាន? តើទឹកដែលប្រើក្នុងការផឹក ចម្អិន ងូត ធ្វើកសិកម្ម និងតម្រូវការដទៃទៀត ត្រូវបានយកមកពីប្រភពផ្សេងគ្នាឬទេ? តើមានទឹកគ្រប់គ្រាន់សម្រាប់តម្រូវការទាំងនេះឬទេ? តើមានប្រភពទឹកឬទឹកស្តុកសម្រាប់គ្រាអាសន្នឬទេ?

### ទៅពិនិត្យមើលកន្លែងដែលប្រជាជនដងទឹក

ប្រភពទឹកផ្សេងៗគ្នាអាចមានបញ្ហានិងដំណោះស្រាយខុសៗគ្នាដែរ។ ពិនិត្យមើលកន្លែងទឹកចេញពីក្នុងដី, អណ្តូង, ប្រភពទឹកលើដី(ទន្លេ ជ្រោះ អូរ បឹង និងត្រពាំង), និងកន្លែងត្រងទឹកភ្លៀង។ នៅកន្លែងប្រភពទឹកនីមួយៗ ចូរចាប់ផ្តើមការពិភាក្សាអំពីវិធីប្រើប្រាស់ទឹក ហើយថាតើមានអ្នកណាសង្ស័យថាទឹកនេះមិនស្អាត(គ្មានសុវត្ថិភាព)ដែរឬទេ។



### គូរផែនទីនៃប្រភពទឹក និងប្រភពចម្លងរោគ

ផែនទីរបស់អ្នកអាចបង្ហាញពីទីតាំងនៃប្រភពទឹកទាំងឡាយដែលទាក់ទងនឹងផ្ទះប្រជាជននិងប្រភពចម្លងរោគ។ ប្រើពណ៌ខុសៗគ្នាដើម្បីបង្ហាញពីប្រភពទឹកស្អាត និងប្រភពដែលកខ្វក់។

# តើទឹករបស់អ្នកមានសុវត្ថិភាពឬទេ?

វាជាការពិបាកក្នុងការដឹងថាទឹកមានសុវត្ថិភាពឬអត់។ វត្ថុមួយចំនួនដែលបង្កឲ្យមានបញ្ហាសុខភាព គឺងាយនឹងដឹងតាមរយៈការក្រឡេកមើល ហិត ឬលិទ្ធទឹក។ ឯវត្ថុដទៃទៀតចាំបាច់ត្រូវធ្វើតេស្ដ៍ទឹក ទើបដឹងថាវាបង្កបញ្ហាសុខភាពឬទេ។ ការយល់អំពីអ្វីដែលធ្វើឲ្យទឹកគ្មានសុវត្ថិភាព និងការធ្វើសកម្មភាពដើម្បីបង្ការទឹកកុំឲ្យកខ្វក់ អាចបង្ការបញ្ហាសុខភាពបានជាច្រើន(មើលជំពូក5)។

## ទឹកថ្លាអាចមិនមែនជាទឹកស្អាត

សកម្មភាពនេះបង្ហាញពីរបៀបដែលទឹកអាចមានវត្ថុគ្រោះថ្នាក់ក្នុងនោះ ទោះបីវាមើលមិន ហិត ឬលិទ្ធមិនដឹងក៏ដោយ។

**ពេលវេលា :** 15 ទៅ 30នាទី

**សម្ភារៈ :** ដបទឹក៤, ភក់, អំបិល, ស្ករ, ទឹកស្អាត

1. មុននឹងចាប់ផ្ដើមសកម្មភាព ចូរចាក់ទឹកឆ្អិនដែលបានបន្សុទ្ធដោយក្លរ ចូលក្នុងដបទាំង៤, ឬប្រើទឹកដែលបានបន្សុទ្ធដោយមធ្យោបាយផ្សេងទៀត។ ដាក់ភក់មួយស្លាបព្រាក្នុងដបមួយ។ ដបមួយទៀតដាក់ស្ករមួយស្លាបព្រា។ ដបទីបីដាក់អំបិលមួយស្លាបព្រា។ ក្រឡុកដបទាំងបីឲ្យបានល្អ។ ដបទីបួនមិនដាក់អ្វីទេ។ យកដបទាំងបួនទៅឲ្យក្រុម។

2. ប្រាប់មនុស្សនៅក្នុងក្រុមឲ្យហិតទឹកនៅក្នុងដបទាំងបួន។ បន្ទាប់មកសុំឲ្យពួកគេផឹកទឹកក្នុងដបណាមួយក៏បាន។ គ្មាននរណាម្នាក់នឹងផឹកទឹកដែលមានភក់នោះទេ ប៉ុន្តែពួកគេនឹងផឹកទឹកក្នុងដបផ្សេងពីនេះ។

3. បន្ទាប់ពីមនុស្សទាំងអស់បានផឹកទឹករួច សួរពួកគេថាហេតុអ្វីមិនផឹកទឹកក្នុងដបដែលមានភក់។ បន្ទាប់មកសួរថាទឹកដែលពួកគេផឹកមានរសជាតិយ៉ាងដូចម្ដេច ហើយពួកគេគិតថានៅក្នុងទឹកគឺជាអ្វី។ តើមានអ្នកណាផឹកទឹកដែលគ្មានដាក់អ្វីទាំងអស់ឬទេ? សួរគាត់ថាហេតុអ្វីបានជាគាត់ដឹងថាវាជាទឹកទទេរគ្មានដាក់អ្វីដែលមើល ហិត និងលិទ្ធមិនដឹង។

4. ចាប់ផ្ដើមពិភាក្សាអំពីអ្វីដែលមាននៅក្នុងទឹក ដែលធ្វើឲ្យទឹកផឹកគ្មានសុវត្ថិភាព។ វាអាចមានដូចជាមេរោគដែលបណ្ដាលឲ្យកើតជំងឺរាក, ដង្កូវក្នុងឈាមដែលបណ្ដាលឲ្យកើតជំងឺស៊ីស្តូសូមីញ៉ា, និងថ្នាំសម្លាប់សត្វល្អិតឬសារធាតុគីមីដទៃទៀត។ តើមានហេតុអ្វីខ្លះដែលជឿថាវត្ថុទាំងនេះអាចមាននៅក្នុងទឹករបស់អ្នក? តើមានវិធីផ្សេងទៀតក្រៅពីការមើល និងហិត ដែលអាចឲ្យយើងដឹងថាទឹកមានសុវត្ថិភាពឬក៏អត់ដែរឬទេ?



### ការធ្វើតេស្តសុវត្ថិភាពទឹក

ការធ្វើតេស្តគុណភាពទឹកត្រូវបានធ្វើឡើងដោយការពិនិត្យគំរូទឹកនៅក្នុងមន្ទីរពិសោធន៍។ ការធ្វើតេស្តនេះបង្ហាញប្រាប់ពីប្រភេទនិងបរិមាណនៃវត្ថុដែលធ្វើឲ្យកខ្វក់ ហើយជាធម្មតាតេស្តនេះចាំបាច់សម្រាប់ការពិនិត្យរកមើលភាពកខ្វក់ដោយសារធាតុគីមី។ ប៉ុន្តែតេស្តនេះអាចត្រូវចំណាយប្រាក់ច្រើន។ ទោះបីការធ្វើតេស្តគុណភាពទឹក មានសារប្រយោជន៍ក៏ដោយ តាមពិតវាមិនសូវសំខាន់ដូចការបង្កើនការយល់ដឹងក្នុងសហគមន៍អំពីបញ្ហាទឹកនិងការការពារប្រភពទឹកដោយប្រុងប្រយ័ត្នទេ (មើលទំព័រ75)។




**តេស្តគុណភាពទឹកបង្ហាញលទ្ធផលតែក្នុងករណីដែលទឹកត្រូវបានធ្វើឲ្យកខ្វក់ក្នុងពេលនិងនៅកន្លែងដែលយកគំរូទឹកប៉ុណ្ណោះ។**

ឧបករណ៍ធ្វើតេស្តខ្លះអាចប្រើក្នុងស្រុកបានដើម្បីធ្វើតេស្តទឹករកមើលមេរោគ។ ឧទាហរណ៍ "តេស្ត H2S" មានតម្លៃទាប(តេស្ត៥ដងស្មើ១ដុល្លា) ហើយផ្តល់លទ្ធផលឆាប់រហ័ស។ ប៉ុន្តែតេស្តនេះជួនកាលមានកំហុសក្នុងការពិនិត្យរកមើលមេរោគគ្រោះថ្នាក់ ហើយវាមិនអាចពិនិត្យរកសារធាតុគីមីឬពងប៉ារ៉ាស៊ីតនៅក្នុងទឹកទេ។

# កែលម្អប្រភពទឹករបស់អ្នក



មុននឹងព្យាយាមបង្កើតប្រភពទឹកថ្មីមួយ អ្នកគួរគិតថាវានឹងងាយស្រួលជាងបើអ្នកធ្វើឲ្យប្រភពទឹកបច្ចុប្បន្នផលិតទឹកឲ្យបានច្រើនជាងមុននិងស្អាតជាងមុន។ នៅពេលធ្វើផែនការកែលម្អប្រភពទឹក ចូរចាប់ផ្តើមដោយការរាយឈ្មោះធនធានក្នុងស្រុកដែលមាន។ ធនធានទាំងនេះរួមមាន ប្រភពទឹក, សម្ភារៈសាងសង់, និងអ្វីដែលសំខាន់បំផុតគឺមនុស្ស។ រាប់បញ្ចូលមនុស្សដែលមានជំនាញក្នុងការសាងសង់អណ្តូងឬអាងទឹក ឬដំឡើងទឹកស្អាត, មនុស្សដែលអាចសម្របសម្រួលសកម្មភាពជាក្រុម និងរៀបចំក្រុមការងារផ្សេងៗ, និងមនុស្សវ័យចំណាស់ដែលនៅចាំថាទឹកត្រូវបានយកយ៉ាងដូចម្តេចកាលពីមុន។

## ការស្វែងរកដំណោះស្រាយ

អ្វីដែលសហគមន៍ធ្វើដើម្បីកែលម្អប្រភពទឹក អាចអាស្រ័យលើបញ្ហាណាដែលបន្ទាន់ជាងគេ ឬបញ្ហាណាដែលងាយស្រួលដោះស្រាយជាងគេ។ ជាការសំខាន់គួរធ្វើផែនការមួយដែលគូសបញ្ជាក់អំពីមូលហេតុឫសគល់នៃបញ្ហា និងបំពេញតម្រូវការមនុស្សគ្រប់គ្នាក្នុងសហគមន៍។

**សម្រេចចិត្តថាប្រភពទឹកនីមួយៗគួរប្រើក្នុងបំណងអ្វី ជាពិសេសបើមានទឹកតិចតួច ឬពិបាកទៅយកទឹក។** ការសាងសង់អាងត្រងទឹកភ្លៀង, អាងស្តុកទឹក, ឬប្រព័ន្ធទឹកស្អាត, អាចជួយនាំទឹកភ្លៀងទៅនៅក្បែរសហគមន៍(មើលទំព័រ86 ទៅ91)។ បើមិនអាចធ្វើដូចនេះ សហគមន៍នៅតែអាចព្យាយាមធ្វើឲ្យមានទឹកស្អាតគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់គ្នា :

- ចែករំលែកការងារទៅយកទឹក
- បង្រៀនមនុស្សគ្រប់គ្នាអំពីវិធីធ្វើឲ្យទឹកមិនឆ្លងមេរោគ (មើលទំព័រ92 ទៅ99)។

ប្រសិនបើមានប្រព័ន្ធទឹករួចជាស្រេច សហគមន៍អាច :

- កែលម្អវិធីយកទឹក
- ជួសជុលបំពង់និងស្នប់ដែលខូច
- ការពារខ្សែទឹកខាងលើនៃប្រភពទឹក
- រិះរកវិធីថ្មីៗទៀតក្នុងការការពារនិងសន្សំសំចៃទឹក

**ប្រសិនបើទឹកអាចត្រូវបានធ្វើឲ្យកខ្វក់ដោយសារធាតុគីមីពុលក្នុងរបៀបណាមួយ គួរប្រើប្រភពទឹកដទៃទៀត** រហូតទាល់តែបានធ្វើតេស្តគុណភាពទឹក។ ប្រសិនបើតេស្តបង្ហាញថាទឹកមានភាពកខ្វក់មែន ចូរបន្តប្រើប្រាស់ប្រភពទឹកដទៃ ហើយរិះរកវិធីលុបបំបាត់អ្វីដែលធ្វើឲ្យទឹកកខ្វក់។ ព្យាយាមបង្ការការបំពុលទឹករបស់អ្នក ដោយទាមទារឲ្យឧស្សាហកម្មបោះចោលកាកសំណល់របស់គេយ៉ាងមានសុវត្ថិភាព និងឲ្យប្រើមធ្យោបាយផលិតកម្មណាដែលស្អាត, និងដោយប្រាប់កសិករឲ្យប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមីតិចតួច។




**បុគ្គលិកសុខាភិបាល និងអ្នកលើកកម្ពស់សុវត្ថិភាពទឹក អាចជួយសហគមន៍ឲ្យកែលម្អសន្តិសុខទឹកបាន។**

# ស្ត្រីជាមនុស្សសំខាន់ក្នុងការរៀបចំផែនការ

ស្ត្រីអាចមានតម្រូវការទឹកខុសពីបុរស។ ជាធម្មតាស្ត្រីគឺជាអ្នកទៅដងទឹក និងបន្សុទ្ធទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ប៉ុន្តែជាញឹកញាប់បុរសគឺជាអ្នកទទួលខុសត្រូវលើការសាង់សង់ និងថែទាំប្រព័ន្ធទឹក។ ដោយសារការងាររបស់បុរសនិងស្ត្រីមានភាពខុសគ្នា ដូច្នេះដើម្បីឲ្យមានប្រយោជន៍ គួររៀបចំផែនការដោយរួមបញ្ចូលស្ត្រីផងដែរ។

## រង្វង់២

សកម្មភាពនេះជួយស្ត្រីឲ្យគិតអំពីតម្រូវការទឹករបស់ខ្លួន និងអំពីរបាំងដែលរារាំងពួកគេមិនឲ្យសម្រេចនូវតម្រូវការនេះ។

**ពេលវេលា :** ៤៥នាទី ទៅ១ម៉ោង

**សម្ភារ: :** ក្រដាសគូររូបធំមួយ ប៊ិច

1. បែងចែកស្ត្រីជាក្រុមៗដែលមានគ្នាមិនលើសពី១០នាក់។ ចែកប៊ិចនិងក្រដាសទៅក្រុមនីមួយៗ។
2. ក្រុមនីមួយៗគួររង្វង់២នៅលើក្រដាស គឺរង្វង់ធំមួយនិងមានរង្វង់តូចមួយទៀតនៅខាងក្នុង។
3. នៅក្នុងរង្វង់ធំ មនុស្សម្នាក់ៗគួររូបឬសរសេរអំពីបញ្ហាទឹក អនាម័យ និងបញ្ហាផ្សេងៗទាក់ទងនឹងសុខភាពដែលវាប៉ះពាល់ដល់សហគមន៍ទាំងមូល។ នៅក្នុងរង្វង់តូច ពួកគេគូររូបឬសរសេរអំពីបញ្ហាផ្សេងៗដែលប៉ះពាល់តែស្ត្រីប៉ុណ្ណោះ។
4. ឲ្យស្ត្រីទាំងអស់ចូលរួមក្រុមជាមួយគ្នាវិញ រួចពិភាក្សា : តើបញ្ហានៅក្នុងរង្វង់ទាំង២ខុសគ្នាដូចម្តេច? តើវាដូចគ្នាយ៉ាងដូចម្តេច? តើអាចមានដំណោះស្រាយអ្វីខ្លះចំពោះបញ្ហាក្នុងរង្វង់ទាំង២? តើយើងអាចធ្វើឲ្យបញ្ហារបស់ស្ត្រីទទួលបានចំណាប់អារម្មណ៍គ្រប់គ្រាន់ដោយរបៀបណា?

សកម្មភាពនេះក៏អាចធ្វើក្នុងចំណោមបុរសនិងស្ត្រីរួមគ្នាដែរ។ ប្រសិនបើបុរសចូលរួមដែរ គួររៀបចំក្រុមមួយដែលមានតែបុរស ហើយឲ្យក្រុមនីមួយៗគួររង្វង់តូច២នៅក្នុងរង្វង់ធំ។ ក្នុងរង្វង់តូចទី១ បញ្ចូលតែបញ្ហាដែលប៉ះពាល់ដល់ស្ត្រី និងរង្វង់តូចមួយទៀត បញ្ចូលតែបញ្ហាដែលប៉ះពាល់ដល់បុរស។



នៅពេលក្រុមទាំងអស់ចូលរួមជាមួយគ្នាវិញ ប្រាប់ឲ្យបុរសគិតអំពីដំណោះស្រាយផ្សេងៗដែលពួកគេអាចធ្វើដើម្បីជួយកែលម្អស្ថានភាពដែលប៉ះពាល់ស្ត្រី។ វាអាចមានដូចជា ការសាងសង់បង្គន់ក្បែរផ្ទះ, ឲ្យបុរសទៅដងទឹក, ចំណាយពេលវេលាច្រើនទៀតនៅជាមួយកូន, ។ល។ និង ។ល។ ដើម្បីឲ្យងាយស្រួល គួរឲ្យស្ត្រីពិភាក្សាអំពីបញ្ហារបស់ពួកគេសិន មុននឹងឲ្យបុរសពិភាក្សាបញ្ហារបស់ស្ត្រី ជាពិសេសនៅក្នុងសហគមន៍ដែលស្ត្រីនិងបុរសអាចមានយោបល់ខុសគ្នាយ៉ាងខ្លាំង។

# របាំងរារាំងការកែលម្អប្រភពទឹករបស់អ្នក

ការដែលសហគមន៍មិនមានទឹកស្អាតគ្រប់គ្រាន់ អាចបណ្តាលមកពីមូលហេតុជាច្រើន។ បញ្ហាទាំងនេះអាចមានដូចជា ការខ្វះខាតប្រាក់, មិនចេះសាងសង់ប្រព័ន្ធទឹក, គ្មានការគាំទ្រពីរដ្ឋាភិបាល, ឬខ្វះការរួបរួមគ្នាក្នុងសហគមន៍។ ដើម្បីឲ្យមានទឹកស្អាតជាអចិន្ត្រៃយ៍ គួរកំណត់រករបាំងរារាំងនានា រួចលុបបំបាត់វាចោលម្តងមួយៗ។ ប្រជាជនទំនងជានឹងចូលរួមកែលម្អ និងថែទាំប្រព័ន្ធរបស់ពួកគេ នៅពេលវា :

- ផ្តល់ការកែលម្អភ្លាមៗ ដូចជាទឹកបន្ថែម, ងាយទៅទទួលយក, ឬមានជំងឺតិច។
- មានតម្លៃទាប។
- មានការផ្លាស់ប្តូរតិចតួចក្នុងសកម្មភាពប្រចាំថ្ងៃ។
- មានការកែលម្អបរិស្ថានក្នុងតំបន់ ដូចជាមានភក់តិច, មូសតិច, ឬមានទឹកបន្ថែមសម្រាប់សួនដំណាំដំណាំតាមផ្ទះ។



**គម្រោងទឹកដែលមានស្ថិរភាព គួរតែលុបបំបាត់ចោលនូវរបាំងរារាំងផ្នែកជម្មជាតិនិងសង្គម និងជួយមនុស្សគ្រប់គ្នានៅក្នុងសហគមន៍យ៉ាងស្មើភាពគ្នា។**

# រិះរកដំណោះស្រាយដែលស្ថិតក្នុងសហគមន៍

ចាប់តាំងពីអតីតកាលមក សហគមន៍នីមួយៗបានបង្កើតវិធីផ្សេងៗក្នុងការស្វែងរក, ដឹកជញ្ជូន, និងការពារទឹក។ ប្រជាជនបានប្រើឈើ(ហៅថា កំណាត់ឈើអាទិទេព) ដើម្បីរកទឹក, បង្កើតឧបករណ៍សម្រាប់យោងទឹក និងជញ្ជូនទឹក, សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនដើម្បីប្រមូលទឹកភ្លៀង, និងដាំដើមឈើដើម្បីការពារប្រភពទឹក និងទីជម្រាល។ ពួកគេក៏បានយល់ព្រមជួយចែករំលែកទឹកដល់សហគមន៍ជិតខាងផងដែរ។ ការការពារទឹក និងការបង្ការជម្លោះដណ្ដើមទឹក អាចជួយថែរក្សាប្រភពទឹកសម្រាប់មនុស្សជំនាន់ក្រោយ, ក្នុងពេលជាមួយគ្នា យើងរៀនពីវិធីថ្មីៗក្នុងការប្រមូលនិងបន្សុទ្ធទឹក ដើម្បីប្រាកដថាវាមានសុវត្ថិភាព និងមានយ៉ាងច្រើន។

## អ្នកភូមិបង្រៀនបុគ្គលិកអភិវឌ្ឍន៍

បុគ្គលិកអភិវឌ្ឍន៍មួយក្រុមបានមកដល់ភូមិមួយក្នុងតំបន់ភ្នំនៃប្រទេសកូឡុំប៊ី ដើម្បីជួយអ្នកភូមិឲ្យប្រយុទ្ធប្រឆាំងនឹងជំងឺរាក តាមរយៈការការពារប្រភពទឹករបស់ខ្លួន។ នៅពេលពួកគេមកពិនិត្យមើលកន្លែងទឹកចេញ ពួកគេឃើញថាគោក្របីនិងសំណឹកដីកំពុងបំផ្លាញកន្លែងទឹកចេញ។ បុគ្គលិកអភិវឌ្ឍន៍បានណែនាំដំណោះស្រាយងាយៗ២យ៉ាង : ព័ទ្ធរបងលួសជុំវិញដើម្បីការពារកន្លែងទឹកចេញ ឬឲ្យស្មៅគោក្របីទាំងនោះស៊ីនៅកន្លែងផ្សេង។

អ្នកភូមិមិនចូលចិត្តគំនិតទាំងនេះទេ។ ពួកគេគិតជាមុនថា របងលួសនេះនឹងត្រូវលួចបាត់ក្នុងពេលដ៏ខ្លី ហើយពួកគេមិនមានដីនិងប្រាក់គ្រប់គ្រាន់ដើម្បីបង្កើតវាលស្មៅដ៏ល្អសម្រាប់គោក្របីទេ។ ប៉ុន្តែដោយមើលឃើញបញ្ហានេះ ពួកគេបាននឹកឃើញដំណោះស្រាយមួយដែលនឹងផ្តល់ផលល្អ។ ពួកគេបានរើសយកថ្ងៃមួយដែលមនុស្សគ្រប់គ្នាក្នុងភូមិចេញមកជួបជុំគ្នាដាំរុក្ខជាតិដែលមានបន្លាស្រួចៗនៅផ្នែកខាងលើនៃកន្លែងចេញទឹក។ រុក្ខជាតិទាំងនេះធ្វើឲ្យគោក្របីខ្លាច ហើយចុះទៅផឹកទឹកនៅទីទំនាបតាមមាត់ទន្លេវិញ។ អ្នកភូមិក៏បានដោះស្រាយបញ្ហានេះ។



# ការពារប្រភពទឹក

ទឹកអាចជាទឹកនៅលើដី(ទន្លេ, អូរ, បឹង, និងត្រពាំង) ឬទឹកក្រោមដី(ទឹកដែលប្រមូលផ្តុំក្រោមដី ហើយចេញមកវិញតាមកន្លែងទឹកចេញ ឬអណ្តូងទឹក)។ ដោយសារទឹកលើដីងាយនឹងកខ្វក់ ដូច្នេះមិនគួរប្រើទឹកនេះជាទឹកផឹកទេ លុះត្រាតែបន្សុទ្ធវាជាមុន(មើលទំព័រ92 ទៅ99)។ ទឹកក្រោមដីជាទូទៅគ្មានមេរោគទេ ព្រោះវាត្រូវបានច្រោះនៅពេលវាជ្រាបឆ្លងកាត់ខ្សាច់និងដី។ ទោះជាយ៉ាងនេះក្តី ទឹកក្រោមដីអាចកខ្វក់ដោយសាររ៉ែធម្មជាតិ ដូចជាហ្វ្លរ៉ៃដ៍(fluoride) ឬអាសេនិក(arsenic) (មើលទំព័រ61), ដោយការធ្លាយបំពង់បង្ហូរកាកសំណល់ អាងទទួលកាកសំណល់ ឬបង្គន់, ដោយការចាក់សំរាម ឬដោយសារធាតុគីមីពុលពីឧស្សាហកម្ម ឬកសិកម្ម។



នៅពេលដីនិងផ្លូវទឹកមិនត្រូវបានថែទាំល្អទេ បរិមាណនៃទឹកក្រោមដីក៏មានកម្រិតទាបដែរ។ នៅកន្លែងដែលបានកាប់ដើមឈើអស់ ទឹកភ្លៀងដែលធ្លាប់តែស្រូបចូលទៅក្នុងដីនិងស្តុកទុកក្នុងនោះ បានហូរទៅទន្លេនិងសមុទ្រអស់។

វិធីល្អបំផុតក្នុងការការពារទាំងទឹកក្រោមដី និងទឹកលើដីមាន ៖

- អនុវត្តកសិកម្មដែលមានស្ថិរភាព (មើលជំពូក15)។
- សាងសង់និងប្រើប្រាស់បង្គន់អនាម័យ (មើលជំពូក7)។
- ការពារតំបន់ដែលទឹកហូរប្រមូលផ្តុំ ដែលហៅថាទីជម្រាល ឬតំបន់ប្រមូលផ្តុំទឹក (មើលជំពូក9)។

នៅពេលមនុស្សតាំងទីលំនៅ និងប្រើប្រាស់ប្រភពទឹក វាក្លាយជាពិបាកនឹងការពារ។ នៅកន្លែងដែលឧស្សាហកម្មធ្វើការងារ ទឹកអាចត្រូវបានប្រើលើសលុប និងធ្វើឲ្យកខ្វក់ ហើយប្រជាជនដែលត្រូវការទឹកបំផុតមិនអាចបង្ការបញ្ហានេះបាន។ បញ្ហាទាំងនេះអាចត្រូវដោះស្រាយបានលុះត្រាតែសហគមន៍រៀបចំសកម្មភាពដើម្បីសន្តិសុខទឹក, ដាក់សម្ពាធលើរដ្ឋាភិបាល, និងអនុវត្តច្បាប់លើឧស្សាហកម្ម។

# អណ្តូងដែលបានការពារ

អណ្តូងទឹកមានច្រើនប្រភេទ។ អណ្តូងងាយបំផុតគឺ**អណ្តូងជីកដោយដៃ។** ប្រភេទអណ្តូងដែលចំណាយប្រាក់ច្រើនបំផុតគឺ **អណ្តូងស្នប់** ដែលប្រើបំពង់តូចមួយខួងជ្រៅទៅក្នុងដី និងមានស្នប់នៅខាងលើសម្រាប់សប់ទឹកយកប្រើ។

អណ្តូងមានប្រយោជន៍តែក្នុងករណីដែលប្រជាជនអាចយកទឹកចេញបានប៉ុណ្ណោះ។ អណ្តូងដែលល្អបំផុតសម្រាប់សហគមន៍ទាំងឡាយ អាស្រ័យលើជម្រៅទឹកក្រោមដី និងធនធានដែលមានសម្រាប់ជីក ខួង និងសាងសង់អណ្តូង។ ក្នុងករណីជាច្រើន អណ្តូងសាមញ្ញរាក់ៗដែលប្រជាជនដងទឹកតាមធុង អាចប្រសើរជាងអណ្តូងថ្លៃៗដែលជីកជ្រៅៗនិងត្រូវការស្នប់សប់។ ការមានអណ្តូងរាក់ៗច្រើន ប្រសើរជាងមានអណ្តូងជ្រៅមួយ ព្រោះបើអណ្តូងមួយរីងទឹក អណ្តូងផ្សេងៗទៀតអាចផ្តល់ទឹកបាន។



**នៅពេលប្រជាជនឈរលើមាត់អណ្តូង ឬប្រើធុងមិនស្អាត ទឹកក្នុងអណ្តូងអាចទៅជាគ្មានសុវត្ថិភាព។**

# ជំហានដើម្បីធ្វើឲ្យអណ្តូងស្នប់ និងអណ្តូងជីក មានសុវត្ថិភាព

មុននឹងជីកអណ្តូង ត្រូវប្រាកដថាវាជាប្រភេទអណ្តូងដែលល្អបំផុតសម្រាប់តម្រូវការមនុស្សគ្រប់គ្នា។ ទឹកអណ្តូងក្លាយជាគ្មានសុវត្ថិភាព បើវាត្រូវបានជីក :

- ក្បែររណ្តៅបង្គន់, លូទឹកស្អុយ, រណ្តៅចាក់សំរាម, ឬបសុសត្វ។
- ក្បែរឧស្សាហកម្ម ដូចជាការជីករ៉ែ ឬការខួងប្រេង, ស្រែចម្ការដែលប្រើថ្នាំសម្លាប់សត្វល្អិត ឬជីគីមី, ឬរណ្តៅសំរាម។
- នៅកន្លែងដែលទឹកសំណល់ឬទឹកហូរលើដីអាចហូរទៅក្នុងអណ្តូង។

អណ្តូងជីករាក់ៗអាចផ្តល់ទឹកល្អ និងមានសុវត្ថិភាព។ ប៉ុន្តែទឹកអាចរីង និងកខ្វក់យ៉ាងងាយ។ ក្នុងរដូវភ្លៀង ទឹក ហូរហៀរលើដីអាចហូរចូលទៅក្នុងអណ្តូងជីក ដោយនាំមេរោគនិងវត្ថុធ្វើឲ្យកខ្វក់ដទៃទៀតជាច្រើន។ មនុស្សឬសត្វដែលប្រើប្រាស់ទឹក អាចចម្លងមេរោគតាមជើងទៅលើអណ្តូងទឹក។ ធុងទឹកនិងខ្សែនៅជុំវិញអណ្តូង ក៏អាចចម្លងមេរោគដែរ ហើយអាចធ្វើឲ្យទឹកកខ្វក់នៅពេលគេទម្លាក់វាទៅក្នុងអណ្តូងទឹក។

ការកែលម្អសាមញ្ញៗ អាចបង្ការការចម្លងរោគ។ ឧទាហរណ៍ ប្រាកដថាប្រើតែធុងទឹកនិងខ្សែដែលស្អាត ប៉ុណ្ណោះនៅពេលទម្លាក់ចូលទៅក្នុងទឹក។ លើកដីនៅជុំវិញប្រហោងអណ្តូង ឬរៀបតដ្ឋនៅលើមាត់អណ្តូង ឬចាក់ស៊ីម៉ង់ជុំវិញមាត់អណ្តូង ដើម្បីឲ្យកាន់តែមានសុវត្ថិភាព។ ការរៀបទ្រនាប់អណ្តូងក៏ជួយបង្ការការរីងទឹក ឬបាក់ស្រុតដែរ ហើយធ្វើឲ្យជីកបានកាន់តែជ្រៅដើម្បីស្តុកទឹកបានច្រើន។ (សម្រាប់ព័ត៌មានអំពីមធ្យោបាយកែលម្អអណ្តូង សូមមើលរូបគំនូរនៅទំព័របន្ទាប់)។

មុននឹងខួងអណ្តូងថ្មី ឬកែលម្អប្រព័ន្ធទឹកដែលប្រើប្រាក់ច្រើន គួរពិចារណាលើការកែលម្អបន្តិចបន្តួចដូចខាងលើនេះដើម្បីធ្វើឲ្យប្រភពទឹកកាន់តែមានសុវត្ថិភាព។

### ការកែលម្អអណ្តូងទឹកចំហរ

**សង់ជណ្តើរថ្មចុះទៅក្នុងអណ្តូងចំហរ ដើម្បីឲ្យប្រជាជនឈរដួសទឹកពីលើកាំជណ្តើរដោយមិនទទឹក។ ត្រូវឈរលើកាំជណ្តើរចុងក្រោយដែលស្ងួត។ មិនត្រូវដើរទៅក្នុងទឹកឡើយ។**



## ការកែលម្អអណ្តូងសាមញ្ញ និងអណ្តូងជីកដោយដៃ



១. អណ្តូងជីកដែលគ្មាន
ការកែលម្អ



២. ពូនដីនៅមាត់អណ្តូង ដើម្បីកុំឲ្យទឹកខាងក្រៅ
ហូរចូល



៣. ព័ទ្ធមាត់អណ្តូងដោយ
ធុងមួយនិងគ្របគម្រប



៤. រៀបឥដ្ឋនៅមាត់អណ្តូង
និងមានឃឿនអណ្តូង



៥. អណ្តូងដែលបានការពារ ដោយមានឃឿន
អណ្តូង និងប្រឡាយទឹក



៦. អណ្តូងដែលបានការពារ ដោយមាន
ឃឿនអណ្តូង ប្រឡាយទឹក និងសួនដំណាំ

**សំខាន់ :** មិនត្រូវផឹកទឹកពីអណ្តូងចំហរដោយផ្ទាល់ទេ។ ការច្រោះទឹកដោយប្រើក្រណាត់ រួចទុកឲ្យវារង មុននឹងផឹក អាចបំបាត់មេរោគបានខ្លះ។ មធ្យោបាយបន្សុទ្ធទឹកមានរៀបរាប់នៅទំព័រ92 ទៅ99។

## ការពារអណ្តូងប្រចាំគ្រួសារ

សហគមន៍ជាច្រើនមានអណ្តូងស្នប់ដែលសាងសង់ដោយរដ្ឋាភិបាល ឬទីភ្នាក់ងារក្នុងស្រុកឬអន្តរជាតិ។ អណ្តូងបិទជិតនិងមានជម្រៅជ្រៅទាំងនេះ ការពារមិនឲ្យមានភាពកខ្វក់ដោយសារមនុស្សនិងសត្វ។ ប៉ុន្តែច្រើនឆ្នាំបន្ទាប់ពីខួងអណ្តូងមក អណ្តូងជាច្រើនមិនអាចប្រើប្រាស់បានទៀតដោយសារស្នប់ខូច, ឬគ្រឿងបន្លាស់ដទៃទៀតមិនអាចរកបាន, ឬប្រជាជនដែលចេះជួសជុលបានចាកចេញ។ វាធ្វើឲ្យមានការផ្គត់ផ្គង់ទឹកស្អាតមិនទៀងទាត់។ ប្រជាជនត្រូវដើរយ៉ាងឆ្ងាយទៅដងទឹក ឬប្រើប្រាស់ទឹកលើដីដែលកខ្វក់ដើម្បីបំពេញតម្រូវការរបស់ខ្លួន។ នៅផ្នែកខ្លះនៃប្រទេសអាហ្វ្រិក អណ្តូងប្រចាំគ្រួសារដែលមានការការពារ កំពុងតែជំនួសអណ្តូងស្នប់។

អណ្តូងដែលមានការការពារ គឺជារណ្តៅដែលជីកដោយដៃ និងរៀបទ្រនាប់រណ្តៅ មានគម្របស៊ីម៉ង់ត៍ ជុំបង្វិលដើម្បីយោងទឹកឡើង និងយឿនអណ្តូង។ វត្ថុទាំងនេះសុទ្ធតែផ្តល់ការការពារដល់អណ្តូងទឹក។ នៅពេលដំឡើងវត្ថុទាំងនេះរួច និងដោយមានការរៀបចំទឹកដោយប្រុងប្រយ័ត្ន នោះអណ្តូងប្រចាំគ្រួសារអាចមានសុវត្ថិភាពខ្ពស់។

## គួរជីកអណ្តូងនៅកន្លែងណា



នៅពេលជីកអណ្តូង សញ្ញាល្អបំផុតដែលថានឹងមានទឹក គឺនៅពេលដែលអ្នកឃើញថាមានអណ្តូងមួយចំនួននៅក្បែរៗនោះ។ ប៉ុន្តែបើអណ្តូងទាំងនេះជាអណ្តូងស្នប់ នោះទឹកប្រហែលជានៅក្នុងដីយ៉ាងជ្រៅមិនអាចជីកដោយដៃបាន។ សញ្ញាល្អមួយទៀតគឺរុក្ខជាតិដែលដុះពេញមួយឆ្នាំដែលត្រូវការទឹកច្រើនដើម្បីរស់។ តំបន់ទំនាបទំនងជាមានទឹកច្រើនជាងតំបន់ខ្ពង់រាប។ ប៉ុន្តែបើអណ្តូងត្រូវបានជីកក្នុងតំបន់ទំនាប នោះចាំបាច់ត្រូវការពារវាកុំឲ្យទឹកភ្លៀងហូរចូល។

## ការរៀបទ្រនាប់អណ្តូង

នៅកន្លែងដីរឹង ការរៀបទ្រនាប់ក្នុងអណ្តូងអាចមិនចាំបាច់ទេ។ ប៉ុន្តែជាការល្អគួររៀបទ្រនាប់យ៉ាងតិច១ទៅ២ម៉ែត្រចាប់ពីផ្ទៃដីចុះក្រោម ដើម្បីបង្ការកុំឲ្យអណ្តូងបាក់ស្រុត។ ប្រសិនបើរៀបទ្រនាប់អណ្តូងទាំងមូល វានឹងធ្វើឲ្យប្រភពទឹកកាន់តែទុកចិត្តបាន ប៉ុន្តែនៅថ្ងៃក្រោយវានឹងពិបាកទៅជ្រៅថែមទៀត។ ការរៀបទ្រនាប់អណ្តូងត្រូវការដុំថ្មតូចធំ ជាមួយឥដ្ឋ ឬស៊ីម៉ង់ត៍។



រៀបទ្រនាប់១ទៅ២ម៉ែត្រខាងលើ



អណ្តូងដែលមានរៀបទ្រនាប់ពេញ

## របៀបធ្វើគម្របអណ្តូង



រៀបចំពុម្ពគម្របអណ្តូង

នៅពេលរៀបទ្រនាប់អណ្តូងរួច ជំហានបន្ទាប់គឺធ្វើគម្របស៊ីម៉ង់ត៍សម្រាប់គ្របអណ្តូង។ គម្របអណ្តូងជួយបង្ការទឹកឬវត្ថុកខ្វក់មិនឲ្យចូលក្នុងអណ្តូង។ វាក៏ធ្វើឲ្យកុមារមានសុវត្ថិភាពក្នុងការប្រើប្រាស់អណ្តូង និងធ្វើជាកន្លែងស្អាតសម្រាប់ដាក់ធុងទឹកនៅពេលប្រជាជនដងទឹក។

❶ គម្របអណ្តូងគួរបិទយ៉ាងជិតណែនល្អនៅលើអណ្តូង។ សម្អាតកន្លែងមួយសម្រាប់ចាក់ស៊ីម៉ង់ត៍ និងគូរវង្វង់មួយដែលត្រូវជាទំហំគម្របអណ្តូង។ រៀបឥដ្ឋមួយជួរជារង្វង់ព័ទ្ធជុំវិញរង្វង់នេះ។ រង្វង់នេះគឺជាពុម្ពនៃគម្របអណ្តូង។



រៀបចំប្រហោងនៅកណ្តាលពុម្ពអណ្តូង និងសរសៃដែក

❷ បង្កើតប្រហោងមួយនៅចំកណ្តាលគម្របអណ្តូងដែលអាចឲ្យធុងទឹកចូលបាន។ ទំហំនៃប្រហោងនេះអាស្រ័យលើប្រភេទធុងយោងដែលអ្នកប្រើ ប៉ុន្តែជាទូទៅប្រហោងនេះគួរធំល្មមអាចដាក់ធុងចំណុះ ១០លីត្រចូលបាន។ ស្គរដែកធំល្មមដែលអាចដាក់ធុងយោងចូលគឺអាចយកមកប្រើសម្រាប់បង្កើតប្រហោងនេះបាន។

❸ រៀបសរសៃដែក(មុខកាត់៣ម.ម) នៅក្នុងពុម្ពគម្របអណ្តូង ដោយរៀបជាក្រឡាចក្រត្រង្គដែលមានចន្លោះពីគ្នា១០ស.ម។



ចាក់ស៊ីម៉ង់ត៍ចូល និងបង្កើតជាមាត់គម្របអណ្តូង

❹ លើកសរសៃដែកដែលរៀបរួចចេញសិន ហើយលាយស៊ីម៉ង់ត៍ដោយប្រើគ្រួស៣ភាគ ខ្សាច់២ភាគ និងស៊ីម៉ង់១ភាគ។ ប្រសិនបើគ្មានគ្រួសទេ ចូរប្រើខ្សាច់៤ភាគ និងស៊ីម៉ង់១ភាគ។ ចាក់ស៊ីម៉ង់ត៍ដែលលាយរួចទៅក្នុងពុម្ពគម្របអណ្តូង ដោយចាក់បំពេញតែពាក់កណ្តាលខាងក្រោម។ ដាក់សរសៃដែកដែលរៀបរួចចូលវិញលើស៊ីម៉ង់ត៍សើមនេះ។ ចាក់ស៊ីម៉ង់ត៍លាយដែលនៅសល់ទៅក្នុងពុម្ព គ្របពីលើសរសៃដែក រួចយកកំណាត់ឈើវាសឲ្យស្មើ។



វាសតម្រឹមមាត់គម្របអណ្តូង

❺ ទុកចោលប្រហែល១ម៉ោង។ ដកពុម្ពស្គរដែកនៅប្រហោងកណ្តាលចេញ រួចចាក់ខ្សាច់សើមទៅក្នុងប្រហោងកណ្តាល។ ដាក់ពុម្ពនៅកណ្តាលចូលវិញលើខ្សាច់ រួចរៀបឥដ្ឋព័ទ្ធជុំវិញពុម្ពកណ្តាលនេះ ដោយទុកចន្លោះ៧៥ម.មពីឥដ្ឋនិងពុម្ពកណ្តាល។ ចាក់ស៊ីម៉ង់ត៍ចូលកន្លែងចន្លោះពីឥដ្ឋនិងពុម្ពកណ្តាលនេះ រួចទុកវាចោលប្រហែលមួយម៉ោង។ មួយម៉ោងក្រោយមក ដកឥដ្ឋនិងពុម្ពកណ្តាលចេញ រួចវាសមាត់គម្របឲ្យស្មើ។ ដើម្បីការពារបានល្អបំផុត គម្របធុងគួរបិទមាត់គម្របអណ្តូងជិតណែនល្អ។



លើកគម្របដាក់ពីលើតួអណ្តូង

❻ ទុកគម្របអណ្តូងចោលមួយយប់ឲ្យរឹង និងទុកចោលរយៈពេលយ៉ាងតិច ៥ថ្ងៃ ដោយដាក់វាក្នុងទឹកជានិច្ច។ មុននឹងលើកគម្របដាក់លើអណ្តូង ពិនិត្យមើលកម្លាំងរបស់វាសិន។ នៅពេលវាជាប់រឹងរយៈពេល៧ថ្ងៃ ចូរកល់វាដោយដុំឈើ៤ដុំ ឬកល់ឲ្យហើបផុតពីដីកម្ពស់៥ស.ម។ បន្ទាប់មកឡើងរាំលើវា! គម្របដែលចាក់បានល្អ នឹងមិនបែកបាក់ឡើយទោះបីមនុស្សច្រើននាក់ឡើងរាំលើវាក៏ដោយ។ ដាក់បាយអរស៊ីម៉ង់ត៍នៅលើរង្វង់តួអណ្តូង រួចលើកគម្របដាក់ឲ្យត្រូវកន្លែងវាដោយប្រុងប្រយ័ត្ន។

## ដុំបង្វិល ធុងទឹក និងច្រវាក់

ដុំបង្វិលស្ថិតនៅចន្លោះបង្គោលសងខាងអណ្តូងដែលមានដៃសម្រាប់បង្វិល ធ្វើឲ្យយើងអាចយោងទឹកមកលើបានយ៉ាងងាយ ហើយវាផ្តល់កន្លែងសម្រាប់រុំខ្សែឬច្រវាក់របស់ធុង។ ប្រសិនបើថ្ងៃក្រោយគេប្រើស្នប់វិញ នោះគេអាចលើកដុំបង្វិលនេះចេញបានយ៉ាងងាយ។ ចងធុងទឹកទៅនឹងចុងខ្សែឬច្រវាក់។ ជាការប្រសើរបំផុត គួរប្រើច្រវាក់ព្រោះមានមេរោគតិចតួចនៅលើវា ប៉ុន្តែវាមានតម្លៃថ្លៃ។ ខ្សែមិនសូវថ្លៃទេ ហើយអាចផ្លាស់ប្តូរបានយ៉ាងងាយប្រសិនបើវាដាច់។




**គំរូនៃការសាងសង់នេះបង្ហាញពីបង្គោលឈើដែលចាក់ទៅក្នុងដីសម្រាប់ទ្រដុំបង្វិល។ ទម្រដុំបង្វិលក៏អាចធ្វើពីឥដ្ឋបានដែរ។**

## ប្រឡាយទឹកនៅយឿនអណ្តូង

ប្រឡាយទឹកនៅយឿនអណ្តូង នាំទឹកដែលសល់ពីការប្រើប្រាស់ជុំវិញអណ្តូង ទៅកន្លែងចោលទឹក។ ធ្វើរបៀបនេះអាចបង្ការកុំឲ្យបរិវេណជុំវិញអណ្តូងក្លាយជាភក់ និងជាកន្លែងមេរោគនិងសត្វល្អិតបន្តពូជ។ មេរោគអាចលូតលាស់នៅក្នុងស្នាមប្រេះបែក ដូច្នេះជាការសំខាន់គឺត្រូវធ្វើយឿនអណ្តូងឲ្យបានល្អ ។




**ចាក់ស៊ីម៉ង់ត៍លាយរួចក្នុងកម្ពស់៧៥ម.ម និងគែមរបស់យឿនអណ្តូង និងប្រឡាយទឹកកម្ពស់១៥០ម.ម។ យឿនទាំងមូលនិងគែមរបស់វា គួរបានដាក់សរសៃដែកទំហំ៣ម.ម ដើម្បីបង្ការការប្រេះបែក។**

# ថែទាំអណ្តូងរបស់អ្នក

ទឹកអណ្តូងងាយនឹងកខ្វក់ណាស់នៅពេលធុងទឹកកខ្វក់ និងខ្សែឬច្រវាក់កខ្វក់ទម្លាក់ទៅក្នុងអណ្តូង។ ដើម្បីរក្សាទឹកអណ្តូងឲ្យស្អាតជានិច្ច ត្រូវដាក់ធុងទឹកមួយនៅជាប់អណ្តូងរហូត ហើយចាក់ទឹកពីធុងទឹកជាប់អណ្តូងនេះចូលក្នុងធុងទឹករបស់អ្នក។ ការលាងសម្អាតដៃមុននឹងដងទឹក និងការសាងសង់របងព័ទ្ធជុំវិញអណ្តូងក៏នឹងជួយបង្ការការធ្វើឲ្យទឹកអណ្តូងកខ្វក់ដែរ។

អ្នកក៏អាចការពារទឹកអណ្តូងរបស់អ្នកបានដែរ នៅពេលអ្នក :

- ដាក់គម្របអណ្តូងត្រឹមត្រូវក្នុងកន្លែងរបស់វា។
- សម្អាតឃឿនអណ្តូងនិងប្រឡាយទឹកឲ្យស្អាតជានិច្ច។
- ដាក់ប្រេងក្នុងដៃរ៉ៃឲ្យបានញឹកញាប់ ដើម្បីឲ្យវាវិលយ៉ាងល្អ។
- កុំឲ្យកុមារលេងនៅអណ្តូងឬស្នប់។
- សង់របងព័ទ្ធជុំវិញអណ្តូងដើម្បីកុំឲ្យសត្វចូល។
- ជ្រើសរើសមនុស្សម្នាក់ឲ្យថែទាំអណ្តូង។



### ប្រឡាយទឹកចេញពីអណ្តូងនិងរូប៊ីណេ

ទោះបីមនុស្សទៅយកទឹកនៅកន្លែងណាក៏ដោយ ទឹកតែងតែខ្ជាតកំពប់ជានិច្ច។ នៅពេលទឹកកំពប់នៅក្នុងជង្ហុក វាក្លាយទៅជាកន្លែងបន្តពូជសម្រាប់សត្វមូស ហើយសត្វនេះផ្ទុកមេរោគជំងឺគ្រុនចាញ់និងជំងឺដទៃទៀត។ អណ្តូង រូប៊ីណេ បំពង់បង្ហូរនៃអាងស្តុកទឹក និងកន្លែងផ្ទុកទឹកដទៃទៀត ត្រូវការប្រឡាយទឹកល្អៗដើម្បីឲ្យទឹកដែលខ្ជាតកំពប់ ហូរទៅឆ្ងាយ ឬហូរទៅក្នុងដី។

ដើម្បីទាញប្រយោជន៍ពីទឹកខ្ជាតកំពប់នេះ គួរដាំដើមឈើឬធ្វើសួនដំណាំនៅត្រង់កន្លែងដែលទឹកចេញពីប្រឡាយមក។ ប្រសិនបើអ្នកមិនអាចដាំដើមឈើឬធ្វើសួនដំណាំទេ អ្នកអាចជីករណ្តៅរួចដាក់ធំថ្ម គ្រួស និងខ្សាច់ដើម្បីស្រូបទឹកទៅក្នុងនោះ។ នេះហៅថា "រណ្តៅជ្រាបទឹក"។ វានឹងជួយបង្ការមូសមិនឲ្យបង្កកំណើត។

**ទឹកទុយោក្នុងសហគមន៍ ដែលមានប្រឡាយបង្ហូរទឹក**

**រណ្តៅជ្រាបទឹក**



# ការបូមទឹកពីអណ្តូង

ដើម្បីយកទឹកឡើងមកលើ ចាំបាច់ត្រូវមានស្នប់។ ស្នប់អាចប្រើថាមពលជាច្រើនប្រភេទ ដូចជាអគ្គិសនី, ឧស្ម័ន, ថាមពលព្រះអាទិត្យ, ឬកម្លាំងមនុស្ស។ ប្រសិនបើស្នប់ពិបាកប្រើ ឬបើវាឧស្សាហ៍ខូច នោះប្រជាជននឹងចាប់ផ្តើមយកទឹកពីប្រភពទឹកគ្មានសុវត្ថិភាព។

## របៀបជ្រើសរើសស្នប់

ស្នប់គ្រប់ប្រភេទមានលក្ខណៈដូចគ្នាមួយគឺ បើវាខូច ប្រជាជននឹងគ្មានទឹក។ សម្រាប់មនុស្សភាគច្រើន ស្នប់ដែលល្អបំផុតគឺជាស្នប់ដែលពួកគេអាចបង្កើត, ដំណើរការ, និងជួសជុលបានដោយខ្លួនឯង ឬអាចជួសជុលបានដោយជាងមេកានិចក្នុងស្រុក។ គួរពិចារណាលើចំណុចខាងក្រោម នៅពេលជ្រើសរើសស្នប់ :

- តើវានឹងអាចប្រើបានទាំងបុរសនិងស្ត្រី និងអាចបំពេញតម្រូវការរបស់ពួកគេបានឬទេ ?
- តើស្ត្រីបានចូលរួមក្នុងការជ្រើសរើសស្នប់ក្នុងសហគមន៍ឬទេ ?
- តើប្រភពថាមពលណាមួយដែលមាន ? ប្រសិនបើស្នប់ត្រូវការប្រើប្រេងថ្លៃ ឬត្រូវការអគ្គិសនីដែលសហគមន៍គ្មាន នោះវានឹងគ្មានប្រយោជន៍អ្វីឡើយ។
- តើស្នប់ងាយនឹងជួសជុលដោយប្រើគ្រឿងបន្លាស់ដែលមានស្រាប់ដែរឬទេ ? តើមួយណាប្រសើរជាង រវាងស្នប់ដែលងាយនឹងខូចប៉ុន្តែអាចជួសជុលបានយ៉ាងងាយនៅក្នុងស្រុក និងស្នប់ដែលមិនងាយនឹងខូចប៉ុន្តែមិនងាយជួសជុលបាននៅក្នុងស្រុក ?

### ស្នប់ប្រើខ្សែ : មានតម្លៃទាប, មធ្យោបាយងាយក្នុងការបូមទឹកឡើងមកលើ

ស្នប់ប្រើខ្សែគឺផ្អែកលើគំរូសាងសង់បែបបុរាណរបស់ប្រទេសចិន។ វាត្រូវបានប្រើដើម្បីបូមទឹកអណ្តូងដែលមានជម្រៅរហូតដល់១៥ម៉ែត្រ ដោយប្រើកម្លាំងតិចតួច។ នៅពេលមនុស្សម្នាក់បង្វិលកង់ វានឹងបូមទឹកឡើងមកលើ រួចបាញ់ចេញមកតាមចំពួយនៅខាងលើអណ្តូង។

ស្នប់ប្រភេទនេះចំណាយប្រាក់តិច និងងាយជួសជុល។ ខ្សែគឺជាផ្នែកមួយដែលងាយនឹងខូច ប៉ុន្តែទោះបីវាគ្រាន់តែជួសជុល(មិនបាច់ជំនួសថ្មី) ក៏ស្នប់នៅតែដំណើរការដែរ។ ប្រជាជនក្នុងបណ្តាប្រទេសជាច្រើនបានយកគំរូតាមស្នប់ប្រើខ្សែនេះ និងប្រើសម្ភារៈដែលពួកគេមាន។ (មើលផ្នែកធនធាន)។




**ស្នប់ប្រើខ្សែត្រូវបានផលិតចេញពីសម្ភារៈដែលមានតម្លៃទាប និងធន់បានយូរ។**

# ការពារកន្លែងទឹកចេញ

កន្លែងទឹកចេញគឺជាកន្លែងដែលទឹកក្រោមដីចេញមកលើផ្ទៃដីដោយធម្មជាតិ។ ដោយសារតែទឹកចេញពីក្នុងដីត្រូវបានច្រោះឆ្លងកាត់ថ្មនិងដី និងហូរយ៉ាងលឿន នោះគេចាត់ទុកវាថាជាទឹកមានសុវត្ថិភាព លើកលែងតែវាត្រូវបានធ្វើឲ្យកខ្វក់នៅលើផ្ទៃដី។ ដើម្បីឲ្យដឹងថាកន្លែងទឹកចេញមួយមានសុវត្ថិភាពឬក៏អត់ ចូររកប្រភពរបស់វា(កន្លែងដែលវាចេញពីដី) និងសួរសំនួរទាំងនេះ ៖

- តើវាជាប្រភពពិតប្រាកដឬទេ ឬក៏មានទឹកអូរឬទឹកលើដីដទៃទៀត ហូរក្រោមដីប៉ុន្តែស្ថិតនៅពីលើកន្លែងទឹកចេញ? បើមែន អ្វីដែលមើលទៅដូចកន្លែងទឹកចេញ តាមពិតគឺជាទឹកលើដីទេ ព្រោះវាគ្រាន់តែហូរកាត់ក្រោមដីក្នុងចម្ងាយខ្លីមួយ។ ក្នុងករណីនេះ វាទំនងជាមានភាពកខ្វក់ ឬក៏ហូរតែក្នុងរដូវភ្លៀងប៉ុណ្ណោះ។
- តើមានប្រហោងធំៗលើថ្មដែលស្ថិតនៅលើកន្លែងទឹកចេញឬទេ? បើមាន ចូរពិនិត្យមើលទឹកពីកន្លែងទឹកចេញ បន្ទាប់ពីមានភ្លៀងធំ។ ប្រសិនបើវាល្អក់ពណ៌សឬពណ៌ខ្មៅ នោះវាទំនងជាមានភាពកខ្វក់ដោយសារទឹកហូរលើដី។
- តើមានលទ្ធភាពនៃការធ្វើឲ្យកខ្វក់នៅក្បែរឬនៅពីលើប្រភពទឹកចេញពីដីឬទេ? លទ្ធភាពនេះមានដូចជា វាលស្មៅគោក្របីស៊ី, បង្គន់រណ្តៅ, អាងទទួលទឹកស្អុយ, ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងជីគីមី, ឬសកម្មភាពរបស់មនុស្សផ្សេងទៀត។
- ក្នុងចម្ងាយ១៥ម៉ែត្រពីកន្លែងទឹកចេញ តើដីមានសភាពជ្រាយឬដូចខ្សាច់ឬទេ? ដីបែបនេះអាចឲ្យទឹកកខ្វក់លើដីហូរចូលទៅក្នុងទឹកក្រោមដី។

## ការពារបរិវេណជុំវិញកន្លែងទឹកចេញ

ការការពារកន្លែងទឹកចេញ ត្រូវការចំណាយតិចជាងការជីកអណ្តូងថ្មី។ នៅពេលកន្លែងទឹកចេញត្រូវបានការពារ នោះគេងាយនឹងតបំពង់នាំទឹកទៅជិតសហគមន៍បាន។ ដើម្បីការពារបរិវេណជុំវិញកន្លែងទឹកចេញ ត្រូវព័ទ្ធរបងជុំវិញបរិវេណអណ្តូង និងជីកប្រឡាយមួយដើម្បីបង្ហូរទឹកកំពប់ចោល។ ធ្វើដូចនេះក៏បង្ការសត្វមិនឲ្យចូលដែរ។

ដាំដើមឈើនៅក្បែរកន្លែងយកទឹក ដើម្បីការពារវាបន្ថែមទៀត។ ដើមឈើនឹងបង្ការសំណឹកដី និងធ្វើឲ្យវាជាកន្លែងគួរឲ្យរីករាយសម្រាប់អ្នកយកទឹក។



# សាងសង់អាងកន្លែងទឹកចេញដើម្បីយកទឹក

អាងកន្លែងទឹកចេញ គឺជាប្រអប់ដាក់ទឹកមួយដែលធ្វើឡើងដោយការរៀបឥដ្ឋកំបោរស៊ីម៉ង់ត៍ ដែលជួយការពារទឹកចេញពីដីមិនឲ្យកខ្វក់។ អាងកន្លែងទឹកចេញក៏ធ្វើឲ្យងាយស្រួលក្នុងការយកទឹកនៅអាងនេះផ្ទាល់ ឬតបំពង់ពីអាងនេះទៅភ្ជាប់នឹងបំពង់ទឹកឬអាងស្តុកទឹករបស់សហគមន៍។ ប្រភេទអាងកន្លែងទឹកចេញ ដែលល្អបំផុតគឺអាស្រ័យលើការរៀបឥដ្ឋ និងលើសម្ភារៈដែលមាន។

### ផ្នែកផ្សេងៗនៃអាងកន្លែងទឹកចេញ




នេះគឺជាប្រភេទមួយនៃអាងកន្លែងទឹកចេញ ដែលមានបង្ហាញពីអ្វីដែលមាននៅក្នុងដី។

### ចាំបាច់លាងសម្អាតបំពង់ និងអាងកន្លែងទឹកចេញ ឲ្យបានញឹកញាប់

ចាំបាច់ត្រូវត្រួតពិនិត្យមើលអាងកន្លែងទឹកចេញ ដើម្បីធានាថាអាងនេះនៅតែបន្តផ្តល់ទឹកដែលមានសុវត្ថិភាព។ ដីល្បាប់, ស្លឹកឈើ, សាកសពសត្វ, និងវត្ថុដទៃទៀត អាចចូលក្នុងបំពង់ និងអាងកន្លែងទឹកចេញ រួចធ្វើឲ្យស្ទះបំពង់ ឬធ្វើឲ្យកខ្វក់ដល់ទឹក។ ដាក់សំណាញ់លួសនៅចុងបំពង់ដែលចូលទៅក្នុងអាងកន្លែងទឹកចេញ ដើម្បីបង្ការវត្ថុមិនស្អាតចូលទៅក្នុងបំពង់។ ការលាងសម្អាតសំណាញ់នេះជាប្រចាំ នឹងធានាថាមានលំហូរទឹកស្មើរហូត។

# ត្រងទឹកភ្លៀង

ការត្រងទឹកភ្លៀងគឺជាវិធីមួយដែលងាយបំផុតនិងមានប្រសិទ្ធភាពបំផុតដើម្បីឲ្យមានទឹកសុវត្ថិភាព។ ទឹកភ្លៀងមានសុវត្ថិភាពសម្រាប់មនុស្សផឹក លើកលែងតែក្នុងតំបន់ដែលមានការបំពុលក្នុងខ្យល់។ ការត្រងទឹកភ្លៀងគឺជាដំណោះស្រាយដ៏ល្អមួយចំពោះការខ្វះខាតទឹកនិងសុវត្ថិភាពទឹក។

ពាងទឹក(អាង/ធុងទឹក)អាចដាក់នៅតាមផ្ទះ។ ដំបូលផ្ទះនឹងប្រមូលទឹកដាក់ក្នុងទរ ហើយចាក់ទៅក្នុងពាងទឹក។ ល្អបំផុតគឺធ្វើដំបូលដែលធ្វើពីស័ង្កសីឬដែកដែលមានភ្លី។ ដំបូលស្បូវប្រហែលជាជាប់ដីច្រើនពេក។ ដំបូលធ្វើពីសំណ ឬជ័រកៅស៊ូ មានសារធាតុគីមីពុលដែលនឹងធ្វើឲ្យទឹកគ្មានសុវត្ថិភាពសម្រាប់ផឹក។ ត្រូវប្រាកដថាធុងដាក់ទឹកភ្លៀង មានភាពស្អាត និងមិនធ្លាប់ដាក់សារធាតុគីមីពុល ដូចជាប្រេងឬថ្នាំសម្លាប់សត្វល្អិតឡើយ។



**ប្រើដំបូលប្រក់ស័ង្កសីដើម្បីត្រងទឹកភ្លៀង**

តំបន់ទំនាបអាចប្រមូលទឹកលើដីនិងទឹកភ្លៀង។ ដើម្បីធ្វើកន្លែងត្រងទឹកនៅទីទំនាប ចូរជីករណ្តៅចុះក្រោម រួចរៀបទ្រនាប់រណ្តៅដោយប្រើឥដ្ឋ ក្បឿង ស៊ីម៉ង់ត៍ ឬក្រណាត់ប្លាស្ទិក។ ទឹកបម្រុងនេះអាចយកប្រើជាទឹកផឹកសម្រាប់សត្វ ឬសម្រាប់ដងយកមកងូត។ ប្រសិនបើទឹកនៅតំបន់ទំនាប ត្រូវបានប្រើសម្រាប់ផឹក គួរធ្វើរបងព័ទ្ធជុំវិញដើម្បីកុំឲ្យសត្វចូល។ ទឹកដែលយកពីតំបន់ទំនាប គួរត្រូវបានសម្អាត(មើលទំព័រ92 ទៅ99) មុននឹងផឹក។

ទឹកដែលត្រងពីដំបូលផ្ទះ ឬទឹកនៅតំបន់ទំនាប អាចស្តុកទុកក្នុងអាងក្នុងដី។ នេះគឺជាវិធីល្អមួយដើម្បីទុកទឹកឲ្យត្រជាក់និងមានគម្រប។ វាក៏ប្រហែលជាមានតម្លៃទាបជាងការសាងសង់ឬទិញធុង/អាងទឹកលើដីផងដែរ។

## ធ្វើឲ្យទឹកភ្លៀងមានសុវត្ថិភាពសម្រាប់ផឹក

ត្រូវរក្សាទុកទឹកភ្លៀងឲ្យផុតពីការធ្វើឲ្យកខ្វក់ ដើម្បីអាចផឹកដោយសុវត្ថិភាព។ ដើម្បីប្រាកដថាទឹកដែលអ្នកត្រង នឹងមានសុវត្ថិភាព :

- សម្អាតអាង(ពាង/ធុង), បំពង់បង្ហូរចូល, ដំបូល, និងទទឹក មុនរដូវភ្លៀងមកដល់។
- មិនត្រូវដាក់ទឹកនៅក្នុងធុងដែលធ្លាប់ដាក់ប្រេង, ថ្នាំសម្លាប់សត្វល្អិត, ឬសារធាតុគីមីពុលដទៃទៀត។
- ឲ្យទឹកភ្លៀងដំបូងហូរលាងសម្អាតធុងចោលសិន។
- គ្របធុង និងដាក់ប្រដាប់ចម្រោះឬក្រណាត់នៅចុងបំពង់បង្ហូរទឹក ដើម្បីកុំឲ្យសត្វ ស្លឹកឈើ និងដីចូល។ វាក៏ជួយបង្ការកុំឲ្យសត្វមូសបន្តពូជផងដែរ។
- បង្ហូរទឹកយកប្រើតាមបំពង់មួយ បើអាច។ ប្រសិនបើប្រើធុងទឹកឬប្រដាប់ដាក់ទឹកផ្សេងទៀត យកមកដងទឹក ត្រូវប្រាកដថាវាមិនប្រឡាក់។
- ដើម្បីឲ្យមានសុវត្ថិភាពបន្ថែម ចូរបន្ថែមក្លរីនទៅក្នុងអាង(មើលទំព័រ99) ឬដាក់ប្រដាប់ចម្រោះទឹកជាប់នឹងអាង(មើលទំព័រ96)។
- មិនត្រូវកូរទឹកឡើយ។ ធ្វើរបៀបនេះដើម្បីកុំឲ្យកករឬមេរោគក្នុងអាង រងនិងធ្លាក់ទៅបាតអាង។
- ជូតសម្អាតដំបូលផ្ទះឲ្យបានញឹកញាប់ នឹងជួយធ្វើឲ្យទឹកភ្លៀងដែលត្រងបាននៅតែស្អាត។

### ការប្រមូលទឹកភ្លៀងនៅក្នុងតំបន់វាលខ្សាច់

វិធីមួយដែលទឹកភ្លៀងត្រូវបានប្រមូលនៅក្នុងតំបន់វាលខ្សាច់ថា នៅភូមិរាចសថាន នៃប្រទេសឥណ្ឌា គឺការប្រើស្រះទឹកក្នុងភូមិដែលហៅថា ណាឌី។ មនុស្សគ្រប់គ្នាក្នុងភូមិ និងសូម្បីតែអ្នកដែលឆ្លងកាត់ក៏អាចប្រើទឹកណាឌីបានដែរ។



មនុស្សគ្រប់គ្នាក្នុងភូមិធ្វើការរួមគ្នាដើម្បីថែទាំទឹកណាឌី។ ច្បាប់ពីបុរាណហាមឃាត់ការកាប់ ដើមឈើនៅក្បែរទឹកណាឌី ឬនៅកន្លែងដែលទឹកភ្លៀងហូរទៅក្នុងណាឌី។ សត្វត្រូវបានដាក់នៅឆ្ងាយពីណាឌី ហើយប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យនោមឬបន្ទោរបង់លាមកនៅក្បែរណាឌីឡើយ។ មួយខែម្តង នៅថ្ងៃដែលគ្មានព្រះច័ន្ទ អ្នកភូមិទាំងមូលធ្វើការរួមគ្នាដើម្បីជីកយកខ្សាច់និងដីល្បាប់ចេញពីណាឌី។ ការជីកណាឌីធ្វើឲ្យវាកាន់តែជ្រៅ និងបំបាត់មេរោគដែលអាចនៅបាតណាឌី។ បន្ទាប់ពីជីករួច អ្នកភូមិទុកទឹកឲ្យរង ដើម្បីឲ្យវាថ្លាឡើងវិញ។ ក្នុងវិធីទាំងនេះ សហគមន៍បានប្រមូលផ្តុំគ្នាការពារទឹករបស់ខ្លួន។

# ការជញ្ជូនទឹកសុវត្ថិភាព

នៅពេលជញ្ជូនទឹកពីប្រភពទឹកទៅកន្លែងដែលប្រជាជនត្រូវការ ត្រូវប្រុងប្រយ័ត្នក្នុងការរក្សាសុវត្ថិភាព និងភាពស្អាត។ ការដងទឹកគឺជាការងារប្រចាំថ្ងៃដ៏លំបាកមួយនៅក្នុងសហគមន៍នានា ហើយជារឿយៗស្ត្រីនិងក្មេងស្រីជាអ្នកធ្វើការងារនេះ។ ការទូលទឹកច្រើននៅលើក្បាល លីនៅលើខ្នង អាចបណ្តាលឲ្យឈឺក្បាលញឹកញាប់, ឈឺខ្នង, គ្រោះថ្នាក់ដល់ឆ្អឹងខ្នង, និងបណ្តាលឲ្យស្ត្រីមានផ្ទៃពោះបាត់បង់ទារកក្នុងផ្ទៃដោយសារការប្រឹងខ្លាំង។

គម្រោងកែលម្អទឹក អាចកាត់បន្ថយបន្ទុកនេះ។ ជួនកាលការផ្លាស់ប្តូរសាមញ្ញៗអាចធ្វើឲ្យការជញ្ជូនទឹកមានលក្ខណៈងាយជាងមុន។ គេអាចសាងសង់ប្រព័ន្ធទឹកដើម្បីលុបបំបាត់ការជញ្ជូនទឹកផ្លូវឆ្ងាយ។ ហើយផ្ទះប្រជាជនអាចសង់នៅក្បែរប្រភពទឹក។ សុខភាពសហគមន៍នឹងបានប្រសើរ ប្រសិនបើបុរសយល់អំពីសារសំខាន់របស់ការងារនេះនៅក្នុងជីវិតគ្រួសារ ព្រមទាំងចែករំលែកការងារយកទឹកនិងជញ្ជូនទឹកពីស្ត្រី។

## ទឹកទុយោ (ប្រព័ន្ធទឹកស្អាត)

ប្រព័ន្ធទឹកទុយោផ្តល់គុណសម្បត្តិជាច្រើន។ ទឹកទុយោកាត់បន្ថយការប្រឈមនឹងការកខ្វក់ ហើយវាមានកន្លែងតិចតួចដែលខ្យងនិងមូសអាចរស់នៅបាន។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធទឹកទុយោដែលត្រូវបានសាងសង់មិនបានល្អ និងប្រើប្រាស់គ្មានសុវត្ថិភាព អាចធ្វើឲ្យការកខ្វក់ទឹកកាន់តែធ្ងន់ធ្ងរជាងគ្មានប្រព័ន្ធទឹកនេះទៀត។ ក្នុងការសាងសង់ប្រព័ន្ធទឹកទុយោ ត្រូវធ្វើផែនការយ៉ាងប្រុងប្រយ័ត្ន ព្រមទាំងយល់អំពីបរិមាណទឹកដែលត្រូវការនិងដែលមាន ហើយថាតើនៅថ្ងៃអនាគតនឹងត្រូវការទឹកប៉ុន្មាននៅពេលសហគមន៍លូតលាស់។

ទឹកទុយោអាចតចេញមកពីប្រភពទឹកណាក៏បាន ប៉ុន្តែកន្លែងទឹកចេញនិងអាងទឹកបម្រុងត្រូវបានគេតចេញញឹកញាប់ជាងគេ។ ប្រភពទឹកដែលមានតម្លៃថោកបំផុតគឺស្ថិតនៅទីទួលពីលើសហគមន៍ ដូច្នេះទំនាញផែនដីនឹងជញ្ជូនទឹកចុះពីទីទួលទៅក្រោម។ ប្រព័ន្ធទឹកទុយោស្ទើរតែទាំងអស់នាំទឹកទៅកាន់អាងស្តុកទឹកធំៗ។ គេអាចបន្សុទ្ធទឹកនៅក្នុងអាងទាំងនេះដោយប្រើក្លរីន ឬប្រើប្រដាប់ចម្រោះ។ បន្ទាប់មកទឹកត្រូវបានតចេញពីអាងស្តុកទឹកធំៗ, ទៅបំពង់ទឹកនៅតាមផ្ទះប្រជាជន, ឬទៅបំពង់ទឹកសាធារណៈនៅក្នុងសហគមន៍។

ប្រព័ន្ធទឹកទុយោត្រូវការថែទាំជាប្រចាំ។ ការកត់ចំណាំអំពីទីកន្លែងដែលបានដាក់បំពង់ អាចបង្ការគ្រោះថ្នាក់ និងធ្វើឲ្យងាយស្រួលរក និងជួសជុលនៅពេលបំពង់បែកធ្លាយ។ ការធ្លាយបំពង់អាចខ្ជះខ្ជាយទឹកជាច្រើន ហូរចូលទៅក្នុងលូ និងធ្វើឲ្យមូសនិងខ្យងមានកន្លែងបន្តពូជ។ ប្រសិនបើបំពង់ត្រូវបានជួសជុលដោយប្រើដើមក្រចៅ ដើមធ្មៃ កប្បាស ឬស្បែកសត្វ, នោះមេរោគអាចលូតលាស់នៅលើវត្ថុទាំងនេះ រួចធ្វើឲ្យកខ្វក់ដល់ទឹកក្នុងបំពង់។



**ផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធទឹកទុយោគឺការធ្វើឲ្យប្រាកដថាមានមនុស្សម្នាក់ទទួលខុសត្រូវលើការជួសជុលបំពង់។**

## បុរសនិងស្ត្រីនិយាយអំពីទឹក

នៅពេលគណៈកម្មការទឹកនៅក្នុងភូមិមួយនៃប្រទេសម៉ិកស៊ិកូ ធ្វើផែនការសាងសង់ប្រព័ន្ធទឹកទុយោភ្ជាប់ពីកន្លែងទឹកចេញមកក្នុងភូមិ ពួកគេបានសម្រេចចិត្តថាពួកគេមានប្រាក់គ្រប់គ្រាន់ក្នុងការដំឡើងបំពង់១សម្រាប់ផ្ទះ២ប្រើរួមគ្នា។ នៅពេលជួបប្រជុំក្នុងភូមិ បុរសៗនៃគណៈកម្មការទឹកបានប្រកាសថា ប្រព័ន្ធទឹកទុយោនឹងដាក់ឲ្យប្រើសម្រាប់ការផឹកនិងចម្អិនអាហារ។ ពួកគេនិយាយថាវាជាដំណឹងល្អសម្រាប់អ្នកភូមិ ព្រោះចាប់ពីពេលនេះទៅស្ត្រីមិនចាំបាច់ចំណាយពេលវេលាពេញមួយថ្ងៃក្នុងការទៅដងទឹកពីទន្លេ យកមកដាំដើម្បីឲ្យមានសុវត្ថិភាពសម្រាប់ផឹកទៀតទេ។



ស្ត្រីនៅក្នុងការប្រជុំ បានក្រោកឈរឡើងរួចសួរថា "ចុះការបោកគក់?"។ បុរសម្នាក់នៃគណៈកម្មការទឹកនិយាយថា "អ្នកអាចបន្តបោកគក់នៅក្នុងទន្លេដូចដែលធ្លាប់បានធ្វើកន្លងមក"។ ស្ត្រីម្នាក់ទៀតក្រោកឈររួចសួរថា "ចុះការងូតទឹកឲ្យក្មេងៗ?"។ បុរសនោះឆ្លើយថា "អ្នកអាចបន្តងូតទឹកឲ្យកូនដូចដែលធ្លាប់បានធ្វើកន្លងមក"។ ស្ត្រីដទៃម្នាក់ទៀតក្រោកឈររួចសួរថា "ចុះសួនដំណាំតាមផ្ទះរបស់យើង? យើងត្រូវការទឹកដើម្បីស្រោចដំណាំ"។

ស្ត្រីទាំងនោះមានអារម្មណ៍ថាសំឡេងរបស់ខ្លួនមិនត្រូវបានគេស្តាប់ឮទេ។ ពួកគេនិយាយថា គ្មានស្ត្រីម្នាក់សោះនៅក្នុងគណៈកម្មការទឹក ដូច្នេះតម្រូវការទឹកសម្រាប់ស្ត្រីនឹងមិនត្រូវបានបំពេញទេ។ ស្ត្រីទាំងនោះទាមទារការចូលរួមក្នុងគណៈកម្មការទឹក និងជួយបង្កើតផែនការថ្មី។ ប្រជាជនដទៃទៀតក៏យល់ព្រម។

គណៈកម្មការទឹកថ្មីបានបង្កើតផែនការមួយខុសពីមុន។ ជំនួសឲ្យការមានបំពង់ទឹក១សម្រាប់ផ្ទះ២ ពួកគេនឹងដំឡើងបំពង់ទឹក១និងអាងសម្រាប់លាងសម្អាត១សម្រាប់ផ្ទះ៦។ ទោះបីស្ត្រីនៅតែដើរទៅយកទឹកក៏ដោយ ពួកគេក៏អាចទៅបោកគក់ ងូតទឹកឲ្យកូនៗ និងលាងពោតនៅក្នុងភូមិតែម្តង។ ទឹកទុយោនឹងត្រូវប្រើសម្រាប់ទឹកផឹក ហើយអាងលាងសម្អាតនឹងត្រូវប្រើសម្រាប់តម្រូវការផ្សេងៗទៀត។ ធ្វើដូចនេះនឹងជួយធានាថាទឹកផឹកនៅស្អាតជានិច្ច។ ហើយពួកគេនឹងយកទឹកប្រើរួច ពីអាងលាងសម្អាត ទៅស្រោចសួនដំណាំតាមផ្ទះ។

ផែនការនេះក៏មានប្រជាប្រិយក្នុងចំណោមពួកបុរសផងដែរ ព្រោះរាល់ថ្ងៃពួកគេនឹងមានកន្លែងសម្រាប់លាងសម្អាតឧបករណ៍នៅពេលត្រឡប់មកពីចម្ការពោតវិញ។ តាមវិធីនេះ អ្នកភូមិបានបំពេញតម្រូវការជាច្រើនរបស់ខ្លួនក្នុងពេលតែមួយ។

# ស្តុកទឹកទុកដោយសុវត្ថិភាព

ប្រសិនបើមិនបានរៀបចំទឹកដោយប្រុងប្រយ័ត្នក្នុងពេលយក ដឹកជញ្ជូន និងរក្សាទុកក្នុងពាង/អាងទេ, វាអាចក្លាយជាកខ្វក់បានយ៉ាងងាយ។ ទឹកដែលទុកនៅក្នុងអាងដែលជញ្ជាំងបែកប្រេះ ឬពាងដែលមានកករ ពាងដែលផលិតមិនបានល្អ ឬគ្មានគម្រប នោះទឹកអាចត្រូវបានធ្វើឲ្យកខ្វក់ដោយសំណល់សត្វនិងមេរោគ។

រឿងស៊ើបអង្កេត : **តើទឹកផឹកត្រូវបានធ្វើឲ្យកខ្វក់ដោយរបៀបណា?**

សកម្មភាពនេះជួយពិនិត្យរកមើលមូលហេតុដែលទឹកចេញពីអណ្តូង, កន្លែងទឹកចេញ, ឬទឹកទុយោ, អាចក្លាយជាកខ្វក់មុនពេលប្រើប្រាស់។ សកម្មភាពនេះអាចត្រូវការមនុស្ស៨នាក់ ឬលើសពីនេះ។

**ពេលវេលា :** កន្លះម៉ោង

❶ អ្នកសម្របសម្រួលពន្យល់ដល់ក្រុមនេះ ថាពួកគេគឺជាអ្នកស៊ើបអង្កេតផ្នែកសុខភាព បន្ទាប់មកផ្តល់សេចក្តីណែនាំឲ្យពួកគេ។ ឧទាហរណ៍ : គ្រួសារចំនួន១០ ដងទឹកផឹកដែលស្អាតចេញពីអណ្តូង។ ពីរបីថ្ងៃបន្ទាប់មក កុមារក្នុងគ្រួសារមួយធ្លាក់ខ្លួនឈឺដោយសារទឹកផឹកមិនស្អាត។ គ្រួសារដទៃទៀតមិនមានបញ្ហាទេ។ ការងាររបស់អ្នកស៊ើបអង្កេតគឺស្វែងរកមូលហេតុថា ហេតុអ្វីបានជាទឹកក្លាយជាកខ្វក់បន្ទាប់ពីយកមកពីអណ្តូង។

❷ អ្នកសម្របសម្រួលស្នើសុំអ្នកស្ម័គ្រចិត្តម្នាក់ទៅ៣នាក់។ អ្នកសម្របសម្រួលពន្យល់អ្នកស្ម័គ្រចិត្តនេះនៅឆ្ងាយពីមនុស្សក្នុងក្រុម(មិនឲ្យស្តាប់ឮ)ថា តួនាទីរបស់ពួកគេគឺផ្តល់"តម្រុយ"នៅពេលក្រុមសួរសំនួរផ្សេងៗដើម្បីស្វែងរកមូលហេតុ។ បន្ទាប់មកអ្នកសម្របសម្រួលអាចប្រាប់ចម្លើយទៅអ្នកស្ម័គ្រចិត្ត ឬសួរពួកគេឲ្យសម្រេចចិត្តយ៉ាងឆាប់រហ័ស ថាហេតុអ្វីទឹកត្រូវបានធ្វើឲ្យកខ្វក់ មុននឹងពួកគេចូលរួមក្នុងក្រុមវិញ។

❸ មនុស្សក្នុងក្រុមប្តូរវេនគ្នាសួរអ្នកស្ម័គ្រចិត្តដែលត្រូវផ្តល់"តម្រុយ" រហូតនរណាម្នាក់អាចទាយត្រូវ ថាវាមកពីមូលហេតុអ្វី។

❹ ប្រសិនបើក្រុមមានទំហំធំ នោះអាចបំបែកជាក្រុមតូចៗទៀត។ ដាក់កម្រិតចំនួនសំនួរ ឧទាហរណ៍ ឲ្យក្រុមតូចៗនីមួយៗឬមនុស្សម្នាក់ៗសួរបានតែ៥សំនួរប៉ុណ្ណោះ។ នរណាម្នាក់ ឬក្រុមណាមួយដែលទាយត្រូវមុនគេ គឺជាអ្នកឈ្នះ។




រៀបចំសកម្មភាពនេះឡើងវិញច្រើនដង ដោយផ្លាស់ប្តូរមូលហេតុដែលទឹកក្លាយជាកខ្វក់។ បន្ទាប់មក អ្នកសម្របសម្រួលអាចដឹកនាំការពិភាក្សាមួយដើម្បីស្វែងរកពីមូលហេតុនានាដែលអាចធ្វើឲ្យទឹកក្លាយជាកខ្វក់។ ជជែកអំពីដំណោះស្រាយផ្សេងៗដែលអាចធ្វើបានដើម្បីការពារទឹកផឹកឲ្យស្អាតជានិច្ច និងជជែកអំពីរបៀបអនុវត្តដំណោះស្រាយទាំងនោះនៅតាមផ្ទះ និងនៅក្នុងសហគមន៍ទាំងមូល។

# ការថែទាំពាង/ធុងទឹកឲ្យស្អាតជានិច្ច

ទឹកដែលស្តុកទុកអាចក្លាយជាគ្មានសុវត្ថិភាពនៅពេលមនុស្សយកដៃប៉ះវា, នៅពេលចាក់ទៅក្នុងធុងមិនស្អាត នៅពេលដីឬធូលីធ្លាក់ចូល, និងនៅពេលដួសទឹកដោយកែវ/ពែងទឹក។ ដើម្បីបង្ការកុំឲ្យទឹកក្លាយជាកខ្វក់នៅផ្ទះ :

- លាងសម្អាតដៃមុនពេលទៅយកទឹកនិងជញ្ជូនទឹក។
- លាងនិងគ្របធុងទឹកដែលប្រើសម្រាប់ជញ្ជូនទឹក។
- លាងសម្អាតពាងស្តុកទឹកជាប្រចាំ។
- ដាក់ពាងទឹក/ធុងដាក់ទឹកឲ្យផុតពីដី និងឲ្យឆ្ងាយពីសត្វ។
- ចាក់ទឹកចេញពីធុងដោយមិនប៉ះមាត់ធុង ឬប្រើបោយស្អាតដៃវែងសម្រាប់ដួសទឹកចេញពីធុង។
- លាងសម្អាតកែវ/ពែងទាំងអស់ដែលប្រើសម្រាប់ផឹក។
- មិនត្រូវរក្សាទុកទឹកក្នុងធុងដែលធ្លាប់បានប្រើសម្រាប់ដាក់ថ្នាំសម្លាប់សត្វល្អិតឬសារធាតុគីមីពុលឡើយ។
- ប្រសិនបើអាច កុំបន្សុទ្ធទឹកឲ្យលើសពីតម្រូវការក្នុងរយៈពេលខ្លី។ សម្រាប់ការផឹកនិងចម្អិនអាហារ ជាធម្មតាវាមិនលើសពី៥លីត្រសម្រាប់មនុស្សម្នាក់ទេ។



**គួរដាក់ធុងទឹកឲ្យបានជិតបំផុតនឹងកន្លែងដែលត្រូវប្រើទឹក។**



### គ្របអាងទឹកនិងធុងទឹក

អាងទឹកនិងធុងទឹកដែលត្រូវបានគ្រប អាចទុកទឹកដោយមានសុវត្ថិភាពជាងស្រះទឹក ព្រោះមូសនិងខ្យងមិនអាចរស់នៅក្នុងអាងដែលបិទជិតទេ។ ការគ្របអាងទឹកក៏ជួយកាត់បន្ថយការបាត់បង់ទឹកពីការហួតផងដែរ។ ប្រសិនបើទឹកត្រូវបានស្តុកទុកនៅក្នុងស្រះឬប្រឡាយ ចូរជីកវាឲ្យបានជ្រៅដើម្បីឲ្យវាប៉ះនឹងខ្យល់តិចតួច ដូច្នេះនឹងកាត់បន្ថយបរិមាណទឹកដែលបាត់បង់ដោយការហួត។

### ជួសជុលការធ្លាយទឹក

ទឹកជាច្រើនអាចត្រូវបានបាត់បង់តាមរយៈការធ្លាយ, ហួត, និងកំពប់។ ដើម្បីសន្សំសំចៃទឹក ត្រូវប្រាកដថាក្បាលរ៉ូប៊ីណេបានបិទនៅពេលមិនប្រើ។ ជួសជុលឬប្តូរថ្មីឲ្យបានឆាប់ចំពោះបំពង់ដែលបែកឬធ្លាយ និងចំពោះធុងទឹកដែលប្រេះ។ ការធ្លាយក៏ជាសញ្ញានៃការចម្លងរោគដែលអាចកើតមាន ព្រោះមេរោគនិងដីដែលចូលក្នុងស្នាមប្រេះរបស់ធុងនិងបំពង់។



# ធ្វើទឹកឲ្យមានសុវត្ថិភាពសម្រាប់ផឹក

ជាការប្រសើរគួរការពារនិងប្រើប្រាស់ប្រភពទឹកដែលមានសុវត្ថិភាព ដូចជាកន្លែងទឹកចេញឬអណ្តូងដែលមានការការពារ ជាជាងការបន្សុទ្ធទឹកដែលយកមកពីប្រភពទឹកដែលមានភាពកខ្វក់ ដូចជាទន្លេ អណ្តូងជីកដោយដៃ)។ ប៉ុន្តែទោះបីទឹកនោះយកមកពីប្រភពណាក៏ដោយ នឹងត្រូវតែឆ្លងកាត់ការបន្សុទ្ធជាមុនប្រសិនបើវាមានភាពកខ្វក់ បើប្រជាជនមិនព្រមផឹកដោយសារពណ៌ឬរសជាតិរបស់វា ឬបើវាត្រូវបានជញ្ជូនយកមករក្សាទុកក្នុងផ្ទះ។ (ទឹកដែលចេញពីប្រព័ន្ធបំពង់ អាងស្តុកទឹក និងអណ្តូង ក៏ត្រូវតែមានការបន្សុទ្ធមុននឹងផឹកដែរ បើវាត្រូវបានធ្វើឲ្យកខ្វក់)។

មធ្យោបាយបន្សុទ្ធទឹកដែលអ្នកជ្រើសរើស នឹងអាស្រ័យលើបរិមាណទឹកដែលអ្នកត្រូវការ តើវត្ថុអ្វីដែលធ្វើឲ្យទឹកកខ្វក់ តើអ្នកនឹងរក្សាទុកវាដោយរបៀបណា និងថាតើធនធានអ្វីខ្លះដែលមាន។ ទោះបីអ្នកបន្សុទ្ធដោយវិធីណាក៏ដោយ ជាការល្អបំផុតគួរទុកទឹកឲ្យរង ទើបចាក់វាទៅក្នុងធុងទឹកមួយទៀត ឬគួរច្រោះទឹកសិនមុននឹងរម្លាប់មេរោគ (មើលទំព័រ94)។ ធ្វើដូចនេះអាចបំបាត់កំទេចល្អិតៗ។ ការច្រោះកំទេចល្អិតៗចោលធ្វើឲ្យការរម្លាប់មេរោគមានភាពងាយស្រួលឬកាន់តែមានប្រសិទ្ធភាព។

មធ្យោបាយដែលបង្ហាញនៅទីនេះ មិនធ្វើឲ្យទឹកមានសុវត្ថិភាពពីសារធាតុគីមីពុលទេ។ ទឹកដែលមានសារធាតុគីមីពុល គឺមិនអាចធ្វើឲ្យមានសុវត្ថិភាពសម្រាប់ផឹក ងូត ឬបោកគក់ទេ។ វាអាចបណ្តាលឲ្យកើតជំងឺមហារីក, កន្ទួលស្បែក, រលូតកូន, ឬបញ្ហាសុខភាពដទៃទៀត។

ដើម្បីធ្វើឲ្យទឹកមានសុវត្ថិភាពពីមេរោគ ត្រូវធ្វើតាមជំហាន២យ៉ាងគឺ ចម្រោះ និងការរម្លាប់មេរោគ :

❶ **ដំបូង**ត្រូវទុកទឹកឲ្យរងរយៈពេលពីរបីម៉ោង បន្ទាប់មកចាក់ទឹកទៅក្នុងធុងស្អាតមួយ ឬច្រោះវា :

ប្រដាប់ចម្រោះ
ប្រើក្រណាត់



... ឬ ...

ប្រដាប់ចម្រោះ
ប្រើធ្យូង៥ស




សម្រាប់ព័ត៌មានបន្ថែមអំពីការទុកទឹកឲ្យរង និងការច្រោះទឹក សូមមើលទំព័រ93 ទៅ97។

❷ **បន្ទាប់មក**រម្លាប់មេរោគក្នុងទឹកដោយប្រើមធ្យោបាយណាមួយដូចខាងក្រោម :



ដាំទឹក

... ឬ ...



ដាក់ក្លរីន

... ឬ ...



រម្លាប់មេរោគដោយ
ប្រើកម្តៅថ្ងៃ

... ឬ ...



ដាក់ក្រូចឆ្មារ
ឬទឹកក្រូច

**សំខាន់ :** លុះត្រាតែបានឆ្លងកាត់ជំហានទី២ ទើបទឹកមានសុវត្ថិភាពអាចផឹកបាន។

# ការទុកទឹកឲ្យរង

ការទុកទឹកឲ្យរង ធ្វើឲ្យកករ, កំទេចកំទីរឹង, មេរោគ, និងដង្កូវ ដែលបង្កឲ្យមានជំងឺមួយចំនួន ធ្លាក់ចុះទៅបាតពាង/ធុង។ ការទុកទឹករយៈពេល៥ទៅ៦ថ្ងៃ នឹងកាត់បន្ថយចំនួនមេរោគនៅក្នុងទឹក។ ប៉ុន្តែមេរោគខ្លះ ដូចជាហ្សាដ្យា នឹងមិនងាប់ទេ ទោះបីទុកទឹកចោលប៉ុន្មានថ្ងៃក៏ដោយ។ ដោយមូលហេតុនេះ បន្ទាប់ពីទុកទឹកឲ្យរងហើយ គួរប្រើមធ្យោបាយមួយទៀតដើម្បីឲ្យទឹកមានសុវត្ថិភាព ដូចជាការច្រោះ, ការដាក់ក្លរីន, ឬការរម្ងាប់មេរោគដោយកម្តៅថ្ងៃ។

## មធ្យោបាយថូ៣

មធ្យោបាយថូ៣ ធ្វើឲ្យទឹករង ដើម្បីឲ្យមេរោគនិងកំទេចកំទីរឹងធ្លាក់ទៅបាតពាង/ធុង។ មធ្យោបាយនេះមានសុវត្ថិភាពជាងការទុកទឹកឲ្យរងដោយប្រើថូតែ១ ប៉ុន្តែវាមិនអាចបំបាត់មេរោគក្នុងទឹកបានទាំងស្រុងទេ។ បន្ទាប់ពីប្រើប្រាស់មធ្យោបាយថូ៣រួច គួររម្ងាប់មេរោគបន្ថែមទៀត(មើលទំព័រ97)។




**ពេលព្រឹក ថ្ងៃទី១ :** ចាក់ទឹកបំពេញថូទី១។ គ្របគម្របនិងទុកវាឲ្យរងរយៈពេល២ថ្ងៃ។

**ពេលព្រឹក ថ្ងៃទី២ :** ចាក់ទឹកបំពេញថូទី២។ គ្របគម្របនិងទុកវាឲ្យរងរយៈពេល២ថ្ងៃ។ កករក្នុងថូទី១ចាប់ផ្តើមធ្លាក់ចុះក្រោម។




**ពេលព្រឹក ថ្ងៃទី៣ :** ចាក់ទឹករងក្នុងថូទី១ ចូលថូទី៣ដែលគ្មានទឹក ដោយប្រាកដថាមិនបានចាក់ទាំងកករនៅបាតថូទី១ទេ។ ឥឡូវនេះទឹកក្នុងថូទី៣ រួចរាល់សម្រាប់ការរម្ងាប់មេរោគ។ ចាក់កករទឹក និងកំទេចកំទីនៅបាតថូទី១ចោល។ លាងសម្អាតថូទី១ រួចចាក់ទឹកបំពេញវិញ។ គ្របគម្របរួចទុកឲ្យរងរយៈពេល២ថ្ងៃ។ (ទឹកក្នុងថូនេះនឹងរង និងរួចរាល់សម្រាប់ការរម្ងាប់មេរោគនៅថ្ងៃទី៥)។




**ពេលព្រឹក ថ្ងៃទី៤ :** ចាក់ទឹករងពីថូទី២ ទៅក្នុងថូទី៣សម្រាប់ការរម្ងាប់មេរោគ។ លាងសម្អាតថូទី២ រួចចាក់ទឹកបំពេញវិញ។

រៀងរាល់ពីរបីថ្ងៃម្តង ត្រូវលាងសម្អាតថូទី៣(ទឹកដែលបានរង)ដោយប្រើទឹកឆ្អិន។ ប្រសិនបើអ្នកប្រើទុយោស្អាតដើម្បីបូមទឹកពីថូមួយទៅថូមួយទៀត នោះវានឹងប៉ះពាល់កករបាតថូតិចតួចជាងការចាក់ចេញពីថូ។

## ការប្រើប្រាស់រុក្ខជាតិ

នៅកន្លែងជាច្រើន ប្រជាជនប្រើប្រាស់រុក្ខជាតិដើម្បីធ្វើឲ្យទឹកមានសុវត្ថិភាពសម្រាប់ផឹក។ នៅអាហ្វ្រិកខាងកើត ប្រជាជនប្រើគ្រាប់ម៉ូរីងហ្គា(Moringa)។ គ្រាប់ម៉ូរីងហ្គាត្រូវបានហៅថាម៉ាលុងហ្គាយ (malunggay) នៅក្នុងប្រទេសហ្វីលីពីន, ហៅថាដើម horseradish (ស្រឡៅងរំដេង) ឬដើមចង្កឹះវាយស្គរនៅក្នុងប្រទេសឥណ្ឌា, និងហៅថាដើមបិនសូលីវ(benzolive)នៅក្នុងប្រទេសហៃទី(Haiti ) និងសាធារណរដ្ឋដូមីនីកាំង(Dominican Republic)។ ដើម្បីប្រើប្រាស់គ្រាប់ម៉ូរីងហ្គា :

១. ហាលគ្រាប់នេះឲ្យស្ងួតរយៈពេល៣ថ្ងៃ។

២. បុកគ្រាប់នេះឲ្យម៉ត់ដូចម្សៅ។ ត្រូវប្រើគ្រាប់ម៉ូរីងហ្គា១៥គ្រាប់សម្រាប់ទឹក២០លីត្រ។



៣. លាយទឹកបន្តិចដើម្បីឲ្យវាទៅជាម្សៅស្អិត រួចដាក់ទៅក្នុងទឹក។

៤. ដើម្បីរំលាយម្សៅស្អិតនេះ ចូរកូរវាក្នុងទឹករយៈពេល៥ទៅ១០នាទី។ កូរវាឲ្យបានឆាប់ដើម្បីឲ្យឆាប់មានប្រសិទ្ធភាព។

៥. គ្របគម្រប រួចទុកវាទៅម្ខាងដើម្បីឲ្យរង។ មួយទៅពីរម៉ោងក្រោយមក ចាក់ទឹកនេះដាក់ធុងស្អាត។ ត្រូវប្រយ័ត្នកុំឲ្យចាក់ដោយទាំងកករក្នុងធុងទីមួយ។

# ការច្រោះទឹក

មានវិធីច្រើនយ៉ាងក្នុងការច្រោះទឹកដើម្បីធ្វើឲ្យមានសុវត្ថិភាពពីមេរោគ។ ប្រដាប់ចម្រោះខ្លះ ដូចប្រដាប់ចម្រោះសេរាមិចខាងក្រោម ទាមទារឧបករណ៍ពិសេស។ ប្រដាប់ចម្រោះដទៃទៀតមិនត្រូវការឧបករណ៍ពិសេសទេ ហើយអាចច្រោះទឹកតិចឬច្រើនបានយ៉ាងងាយ មុននឹងរម្ងាប់មេរោគ។



## ក្រណាត់ចម្រោះ

នៅប្រទេសបង់ក្លាដេសនិងឥណ្ឌា ក្រណាត់ត្បាញយ៉ាងល្អត្រូវបានប្រើសម្រាប់ច្រោះចេញនូវមេរោគជំងឺអាសន្នរោគចេញពីទឹកផឹក។ ដោយសារមេរោគជំងឺអាសន្នរោគភ្ជាប់ខ្លួនជាមួយសត្វល្អិតៗដែលរស់នៅក្នុងទឹក ទើបការច្រោះសត្វល្អិតៗទាំងនេះចេញ ក៏ច្រោះមេរោគជំងឺអាសន្នរោគស្ទើរតែទាំងអស់ចេញដែរ។ មធ្យោបាយនេះក៏ច្រោះដង្កូវហ្គីណេផងដែរ។

អ្នកអាចធ្វើក្រណាត់ចម្រោះពីកន្សែង ឬក្រណាត់ផ្សេងៗ ដូចជាក្រណាត់ដែលប្រើសម្រាប់ធ្វើសារី(សម្លៀកបំពាក់ប្រពៃណីស្ត្រីឥណ្ឌា)។ ក្រណាត់ចាស់មានប្រសិទ្ធភាពជាងក្រណាត់ថ្មី ព្រោះសរសៃៗដែលសឹកដាច់ ធ្វើឲ្យចន្លោះប្រហោងក្នុងក្រណាត់កាន់តែមានទំហំតូច ហើយច្រោះបានល្អជាង។

១. ទុកទឹកឲ្យរងក្នុងធុងមួយ ដើម្បីឲ្យកំទេចកំទីរឹងធ្លាក់ទៅបាតក្រោម។

២. បត់ក្រណាត់៤ផ្នត់ រួចទាញសន្ធឹង ឬចងជុំវិញមាត់ធុងមួយទៀត។

៣. ចាក់ទឹកយឺតៗពីលើក្រណាត់ ចេញពីធុងទី១ ចូលទៅធុងទី២។

ត្រូវប្រើក្រណាត់តែម្ខាង(កុំត្រឡប់ក្រណាត់ពីលើចុះក្រោម) ដើម្បីកុំឲ្យមេរោគចូលទៅក្នុងធុងទី២។ បន្ទាប់ពីប្រើក្រណាត់រួច ត្រូវលាងសម្អាតវា រួចហាលថ្ងៃឲ្យស្ងួត។ ធ្វើរបៀបនេះនឹងសម្លាប់មេរោគដែលជាប់ក្នុងសាច់ក្រណាត់។ ក្នុងរដូវភ្លៀង គួររម្ងាប់មេរោគក្នុងក្រណាត់ដោយប្រើទឹកសារ៉ែល។ ត្រូវប្រាកដថានឹងលាងសម្អាតធុងដែលដាក់ទឹកចម្រោះ យ៉ាងហោចរៀងរាល់២ទៅ៣សប្តាហ៍ម្តង។

## ប្រដាប់ចម្រោះសេរាមិច

គេអាចធ្វើប្រដាប់ចម្រោះតូចមួយពីដីឥដ្ឋដុតរួច ស្រោបដោយទឹកប្រាក់ស្អិត(សារធាតុសម្លាប់មេរោគ)។ ដោយការបង្ហាត់បង្ហាញបន្តិចបន្តួច ជាងស្មូនថ្នាំងអាចធ្វើប្រដាប់ចម្រោះទាំងនេះបានយ៉ាងងាយ។ (សម្រាប់ព័ត៌មានបន្ថែម សូមអានផ្នែកធនធាន)។




**ប្រដាប់ចម្រោះសេរាមិចត្រូវបានប្រើប្រាស់នៅក្នុងធុងជ័រមួយ**

## វិធីធ្វើប្រដាប់ចម្រោះប្រើធ្យូង

យើងអាចធ្វើប្រដាប់ចម្រោះដោយមិនពិបាកទេ ហើយវាច្រោះមេរោគស្ទើរតែទាំងអស់ពីទឹកដែលមានបរិមាណតិច។

**សម្ភារៈ :** ធុងទឹកជ័រឬដែកចំនួន២ ញញួរ១និងដែកគោលធំ១ឬ២ ខ្សាច់គ្រើម(មិនមែនខ្សាច់សមុទ្រទេ)១ធុង ធ្យូងឧស១ភាគ៤នៃធុង

1. ចោះរន្ធតូចៗនៅបាតធុងទី១។ លាងសម្អាតធុង។ ឥឡូវវាក្លាយជាធុងចម្រោះ។

2. លាងខ្សាច់ក្នុងទឹក រួចបង្ហូរទឹកចេញពីខ្សាច់ រហូតទាល់តែឃើញថាទឹកដែលហូរចេញពីខ្សាច់មានសភាពថ្លា។

3. កិនធ្យូងជាបំណែកតូចៗ។ ធ្យូងសកម្មធ្វើការបានល្អបំផុត ប៉ុន្តែធ្យូងឧសធម្មតាក៏ធ្វើការបានដែរ។ មិនត្រូវប្រើដុំធ្យូងថ្មឡើយ! ព្រោះវាពុល!




4. ចាក់ខ្សាច់ដែលលាងស្អាតទៅក្នុងបាតធុងចម្រោះ កម្រាស់៥ស.ម រួចចាក់ទឹកពីលើខ្សាច់នេះ។ ទឹកគួរតែអាចស្រក់ចេញតាមរន្ធតូចៗបាន។ បើទឹកចេញមិនរួចទេ ត្រូវចោះរន្ធឲ្យធំជាងនេះ។ បើមានបញ្ហានេះកើតឡើង ត្រូវយកខ្សាច់ចេញវិញ ដាក់ក្រណាត់ស្តើងពីលើរន្ធទាំងនោះ រួចចាក់ខ្សាច់ចូលវិញ។

5. ចាក់កំទេចធ្យូងពីលើខ្សាច់ កម្រាស់៨ស.ម។ បន្ទាប់មកចាក់ខ្សាច់បន្ថែមទៀតពីលើធ្យូង ចាក់ខ្សាច់រហូតនៅដល់តែ១០ស.មពីមាត់ធុងចម្រោះ។

6. ដាក់ឈើទ្រ២នៅលើធុងទី២ រួចដាក់ធុងចម្រោះពីលើឈើទ្រទាំង២។ ចាក់ទឹកក្នុងធុងចម្រោះឲ្យបានច្រើនដង រហូតទាល់តែទឹកចេញមកមានសភាពថ្លា។ ឥឡូវនេះប្រដាប់ចម្រោះរួចរាល់សម្រាប់ប្រើប្រាស់ហើយ។

7. ដើម្បីប្រើប្រាស់ប្រដាប់ចម្រោះ ត្រូវយកទឹកដែលអ្នកបានទុកឲ្យរង មកចាក់ចូលក្នុងធុងចម្រោះ។ ផឹកទឹកដែលបានច្រោះរួច ដើម្បីឲ្យមានសុវត្ថិភាពបំផុត គួរសម្លាប់មេរោគបន្ថែមទៀតបន្ទាប់ពីច្រោះរួច (មើលទំព័រ97 ទៅ99)។

ដោយហេតុថាមេរោគដែលត្រូវបានច្រោះចេញ នឹងលូតលាស់នៅលើធ្យូង នោះជាការសំខាន់គឺត្រូវយកធ្យូងចេញមកលាងសម្អាតរៀងរាល់ពីរបីសប្តាហ៍ម្តងបើប្រើប្រដាប់ចម្រោះរាល់ថ្ងៃ ឬសម្អាតរាល់ពេលបើមិនបានប្រើពីរបីថ្ងៃ។

## វិធីធ្វើប្រដាប់ចម្រោះតាមផ្ទះដោយប្រើខ្សាច់

នេះគឺជាប្រដាប់ចម្រោះដែលមានសុវត្ថិភាពបំផុតមួយ, មានប្រសិទ្ធភាពបំផុត, និងជាវិធីដែលចំណាយតិចបំផុតក្នុងការច្រោះទឹកប្រើប្រាស់ក្នុងគ្រួសារ។ ប្រដាប់ចម្រោះនេះអាចបន្សុទ្ធទឹកគ្រប់គ្រាន់សម្រាប់គ្រួសារតូចមួយ (យ៉ាងហោច៥០លីត្រក្នុង១ថ្ងៃ)។

1. លាងសម្អាតធុងទឹកចំណុះ២០០លីត្រដែលទឹកចូលមិនបាន រួចរម្ងាប់មេរោគដោយម្សៅសាវ៉ែល។ ប្រាកដថាធុងទឹកនេះមិនធ្លាប់បានដាក់សារធាតុគីមីពុលទេ។

2. ចោះរន្ធមួយសម្រាប់ដាក់ក្បាលរ៉ូប៊ីណេ ដែលស្ថិតនៅប្រហែល១ភាគ៤ ទៅ១ភាគ៣ ផ្នែកខាងលើនៃធុង។ រន្ធនេះគួរចោះល្មមតែត្រូវនឹងទំហំក្បាលរ៉ូប៊ីណេប៉ុណ្ណោះ។ (ឧទាហរណ៍ ប្រសិនបើក្បាលរ៉ូប៊ីណេមានមុខកាត់១២ម.ម គួរចោះរន្ធទំហំ១២ម.មដែរ)។

3. ដាក់ក្បាលរ៉ូប៊ីណេភ្ជាប់នឹងរន្ធ ដោយបិទជ័រការឲ្យវាជាប់ណែនល្អ។ ប្រសិនបើប្រើធុងធ្វើពីឥដ្ឋ ត្រូវបិទស៊ីម៉ង់ត៍ជំនួសវិញ។

4. ត្រៀមបំពង់ទុយោមួយដែលអាចបត់បែនបាន។ ចោះរន្ធតូចៗនៅលើបំពង់ទុយោ ត្រឹម៣៥ ស.មចុះក្រោម បិទចុងបំពង់ឲ្យជាប់ ហើយវេញវាជារង្វង់ រួចដាក់វានៅបាតធុងទឹក ដោយដាក់ឲ្យរន្ធតូចៗនោះផ្កាប់ចុះក្រោម។

5. តភ្ជាប់ចុងម្ខាងទៀត(ដែលគ្មានចោះរន្ធតូចៗ)នៃបំពង់ទុយោ ទៅនឹងក្បាលរ៉ូប៊ីណេ។ បិទតំណនេះដោយប្រើអង្កុំគៀបបំពង់ឬខ្សែលួស។

6. ចាក់គ្រួសចូលទៅបាតធុងឲ្យមានកម្រាស់៧ស.ម ដើម្បីគ្របបំពង់ទុយោ។ គ្របស្រទាប់គ្រួសនេះដោយក្រណាត់ស្អាតមួយផ្ទាំង រួចចាក់ខ្សាច់ទន្លេដែលបានលាងស្អាត ចូលពីលើក្រណាត់នេះ រហូតនៅសល់កម្ពស់តែ១០ស.មពីក្រោមក្បាលរ៉ូប៊ីណេ។ បន្ទាប់មកគ្របខ្សាច់ដោយក្រណាត់ស្អាតមួយទៀត។

7. ធ្វើគម្របធុង ដោយចោះរន្ធមួយសម្រាប់ចាក់ទឹកចូល។ ដាក់ថ្មសំប៉ែតស្ដើងមួយដុំ ឬចានមួយពីក្រោមរន្ធគម្របដើម្បីបង្ការកុំឲ្យខ្សាច់ខ្ចាតនៅពេលចាក់ទឹកចូល។

បាញ់ទឹកឬជះទឹកសម្អាតប្រដាប់ចម្រោះនេះ។ នៅពេលលាងស្អាតហើយ ប្រដាប់ចម្រោះនេះរួចរាល់សម្រាប់ប្រើប្រាស់បាន។

ធុងទឹកចំណុះ២០០លីត្រ



### ដើម្បីប្រើប្រាស់និងថែទាំប្រដាប់ចម្រោះទឹកដោយប្រើខ្សាច់

បន្ទាប់ពីប្រើប្រាស់បានពីរបីថ្ងៃ ស្រទាប់ស្លែ(បាក់តេរី និងសារាយ)នឹងកើតឡើងនៅពីលើខ្សាច់។ ស្រទាប់ស្លែនេះជួយបន្សុទ្ធទឹកទេ ដូច្នេះកុំយកវាចេញ។ ដើម្បីឲ្យស្រទាប់ស្លែនេះធ្វើការ ត្រូវចាក់ទឹកឲ្យលិចខ្សាច់ជានិច្ច។ (ហេតុដូច្នេះហើយបានជាគេដាក់ក្បាលរូប៊ីណេនៅពីលើស្រទាប់ខ្សាច់)។ ចាក់ទឹកបំពេញប្រដាប់ចម្រោះរាល់ថ្ងៃ ហើយបង្ហូរទឹកយកប្រើប្រាស់តែបន្តិចបន្តួចប៉ុណ្ណោះ។ ប្រសិនបើបង្ហូរទឹកចេញពីប្រដាប់ចម្រោះអស់ នោះវានឹងមិនសូវមានប្រសិទ្ធភាពទេ ហើយចាំបាច់ត្រូវលាងសម្អាតប្រដាប់ចម្រោះនិងរៀបវាឡើងវិញ។

ទុកទឹកឲ្យរងល្អ មុននឹងចាក់ទៅក្នុងប្រដាប់ចម្រោះ។ ធ្វើដូចនេះនឹងកាត់បន្ថយតម្រូវការលាងសម្អាតប្រដាប់ចម្រោះ ព្រោះទឹកដែលចាក់ចូលមានសភាពរងស្រាប់។ នៅពេលអ្នកចាក់ទឹក គួរចាក់វាឲ្យខ្លាំងៗដូចទឹកជ្រោះធ្លាក់ នោះវានឹងមានខ្យល់នៅក្នុងទឹក ហើយធ្វើឲ្យទឹកមានរសជាតិប្រសើរឡើង។

នៅពេលដែលទឹកចេញពីរូប៊ីណេ មានល្បឿនយឺត ចូរលាងសម្អាតប្រដាប់ចម្រោះ។ បង្ហូរទឹកចេញឲ្យអស់ រួចយកស្រទាប់ស្លែចេញ ថែមទាំងស្រទាប់ខ្សាច់ប្រហែល១ស.មផងដែរ។ បន្ទាប់ពីលាងសម្អាតវាច្រើនដង នៅពេលយកខ្សាច់ចេញអស់ច្រើនជាងពាក់កណ្តាល ត្រូវប្តូរខ្សាច់និងថ្មៗ លាងសម្អាតថ្មនិងខ្សាច់ថ្មីរួចរៀបឡើងវិញ។ អាចលាងសម្អាត និងផ្លាស់ប្តូរខ្សាច់ថ្មី ១ទៅ២ដងក្នុង១ឆ្នាំ។

### ប្រដាប់ចម្រោះជាតិអាសេនិក

ដើម្បីច្រោះជាតិអាសេនិកចេញពីទឹក ចូរដាក់ដែកគោលមួយចាននៅលើប្រដាប់ចម្រោះ។ ប្រើដែកគោលទំហំតូចបំផុត ទម្ងន់ពី៣ទៅ៥គ.ក្រ។ មិនត្រូវប្រើដែកគោលដែលមានស្រោបស័ង្កសីទេ ព្រោះដែកគោលត្រូវតែអាចមានច្រេះ ដើម្បីអាចច្រោះបាន។ ជាតិអាសេនិកតោងទៅលើដែកគោលច្រេះ ហើយត្រូវបានយកចេញពីទឹក។ (សម្រាប់ព័ត៌មានបន្ថែម សូមមើលផ្នែកធនធាន)។

## ការរម្ងាប់មេរោគក្នុងទឹក

ការរម្ងាប់មេរោគក្នុងទឹក សម្លាប់មេរោគនិងដង្កូវ ធ្វើឲ្យទឹកមានសុវត្ថិភាពសម្រាប់ផឹក។ មធ្យោបាយល្អបំផុតគឺការដាំឲ្យពុះ, ហាលថ្ងៃក្តៅ, ឬប្រើក្លរីន។

**សំខាន់ ៖** មធ្យោបាយទាំងនេះនឹងមិនធ្វើឲ្យទឹកមានសុវត្ថិភាពពីសារធាតុគីមីពុលទេ។

### ការដាំទឹក

ដាំទឹកឲ្យពុះយ៉ាងកញ្ជ្រោល។ នៅពេលវាចាប់ផ្តើមពុះ គួរទុកឲ្យវាពុះរយៈពេល១នាទីពេញ មុននឹងលើកកំសៀវចេញ។ នៅតំបន់ភ្នំខ្ពស់ៗ គេត្រូវដាំទឹកឲ្យពុះរយៈពេល៣នាទី ដើម្បីសម្លាប់មេរោគ ព្រោះនៅតំបន់ភ្នំ ទឹកពុះនៅសីតុណ្ហភាពទាបជាងធម្មតា។

ការដាំទឹកឲ្យពុះធ្វើឲ្យទឹកផ្លាស់ប្តូររសជាតិ។ បន្ទាប់ពីទឹកពុះចុះត្រជាក់ ចូរចាក់វាទៅក្នុងដប ហើយក្រឡុកឲ្យខ្លាំងៗ។ ការក្រឡុកនឹងធ្វើឲ្យមានខ្យល់នៅក្នុងទឹក ហើយវាបង្កើនរសជាតិរបស់ទឹក។

នៅតំបន់ដែលខ្វះខាតឧស ការដាំទឹកអាចជាការពិបាក។ គួរដាំទឹកបន្ទាប់ពីដាំស្លរួច ប៉ុន្តែត្រូវដាំមុនភ្លើងរលត់អស់។ ធ្វើដូចនេះជួយកាត់បន្ថយការប្រើប្រាស់ឧស។



**ការដាំទឹកឲ្យពុះរយៈពេល១នាទី ធ្វើឲ្យទឹកមានសុវត្ថិភាពពីមេរោគ។**

## វិធីរម្លាប់មេរោគក្នុងទឹកដោយកម្ដៅថ្ងៃ

ការរម្លាប់មេរោគដោយកម្ដៅថ្ងៃ គឺជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការរម្លាប់មេរោគក្នុងទឹក ដោយប្រើតែកម្ដៅថ្ងៃនិងដបទឹកប៉ុណ្ណោះ។ ការច្រោះទឹក ឬទុកទឹកឲ្យរងជាមុន កាត់បន្ថយរយៈពេលនៃរម្លាប់មេរោគដោយកម្ដៅថ្ងៃ។ ការរម្លាប់មេរោគក្នុងទឹកដោយកម្ដៅថ្ងៃ មានប្រសិទ្ធភាពបំផុតនៅក្នុងតំបន់ដែលនៅក្បែរខ្សែអេក្វាទ័រ ព្រោះនៅទីនោះមានកម្ដៅខ្លាំងបំផុត។ ប្រសិនបើអ្នករស់នៅក្នុងតំបន់ក្បែរប៉ូលខាងជើងឬខាងត្បូង នោះអ្នកនឹងត្រូវការពេលវេលាច្រើនក្នុងការរម្លាប់មេរោគ។ (សម្រាប់ព័ត៌មានបន្ថែមអំពីការរម្លាប់មេរោគដោយកម្ដៅថ្ងៃ សូមមើលផ្នែកធនធាន)។



❶ លាងសម្អាតដបកែវឬដបប្លាស្ទិក ឬថង់ប្លាស្ទិក។ ល្អបំផុតគឺដបដែលធ្វើពីប្លាស្ទិក PET។

❷ ចាក់ទឹកចូលពាក់កណ្ដាល រួចក្រឡុករយៈពេល២០វិនាទី។ វានឹងធ្វើឲ្យមានពពុះខ្យល់នៅក្នុងទឹក។ បន្ទាប់មកចាក់ទឹកបន្ថែមឲ្យពេញ។ ពពុះខ្យល់ទាំងនេះនឹងជួយរម្លាប់មេរោគក្នុងទឹកឲ្យបានឆាប់។



❸ ដាក់ដបទឹកនៅត្រង់ណាដែលគ្មានម្លប់ ហើយគ្មានមនុស្សនិងសត្វរំខានវា ដូចជា នៅលើដំបូលផ្ទះជាដើម។ ទុកដបហាលថ្ងៃរយៈពេលយ៉ាងតិច ៦ម៉ោងបើមានថ្ងៃពេញ ឬរយៈពេល២ថ្ងៃបើមេឃស្រទុំពពក។

❹ ផឹកទឹកពីដបដោយផ្ទាល់។ ធ្វើដូចនេះជៀសវាងការប្រឡាក់ពីដៃឬកែវទឹក។

❺ ការរម្លាប់មេរោគដោយកម្ដៅថ្ងៃ អាចធ្វើបានកាន់តែឆាប់ ដោយដាក់ដបទាំងនោះនៅក្នុងចង្ក្រានប្រើពន្លឺថ្ងៃ(មើលទំព័រ364)។

❻




**ប្រើក្រូចឆ្មារឬក្រូចទូទៅ១ផ្លែក្នុងទឹក១លីត្រ**

### ទឹកក្រូចឆ្មារ

ដាក់ទឹកក្រូចឆ្មារ១ផ្លែក្នុងទឹកផឹក១លីត្រ រួចទុកស្ងៀមរយៈពេល៣០នាទី។ ធ្វើដូចនេះនឹងសម្លាប់មេរោគជំងឺអាសន្នរោគស្ទើរតែទាំងអស់ និងមេរោគដទៃទៀតមួយចំនួនផងដែរ។ វិធីនេះមិនអាចធ្វើឲ្យទឹកមានសុវត្ថិភាពទាំងស្រុងទេ ប៉ុន្តែនៅតំបន់ប្រឈមនឹងជំងឺអាសន្នរោគ វិធីនេះប្រសើរជាងមិនធ្វើអ្វីសោះ។ ការដាក់ទឹកក្រូចឆ្មារក្នុងទឹក មុននឹងរម្លាប់មេរោគដោយកម្ដៅថ្ងៃឬប្រើមធ្យោបាយថូ៣ នឹងធ្វើឲ្យទឹកកាន់តែមានសុវត្ថិភាព។

### ក្លរីន

ក្លរីនមានតម្លៃថោក ហើយងាយប្រើប្រាស់ក្នុងការសម្លាប់មេរោគភាគច្រើននៅក្នុងទឹកផឹក។ ប៉ុន្តែប្រសិនបើប្រើក្លរីនតិចពេក វានឹងមិនអាចសម្លាប់មេរោគទេ។ ប្រសិនបើប្រើក្លរីនច្រើនពេក ទឹកនឹងមានរសជាតិមិនល្អ។ ល្អបំផុតគួរប្រើក្លរីននៅក្នុងប្រព័ន្ធទឹកស្អាត(ទឹកទុយោ)នៅក្នុងសហគមន៍ ព្រោះគ្រួសារនីមួយៗ មិនងាយនឹងប្រើប្រាស់ក្លរីនបានត្រឹមត្រូវគ្រប់ពេលទេ។ ដើម្បីប្រើក្លរីនក្នុងការរម្លាប់មេរោគក្នុងទឹកនៅតាមផ្ទះ សូមធ្វើតាមសេចក្ដីណែនាំដែលមាននៅទំព័របន្ទាប់។

ការប្រើក្លរីនច្រើនធ្វើឲ្យមានគ្រោះថ្នាក់ដល់មនុស្សនិងបរិស្ថាន ប៉ុន្តែជាធម្មតាបរិមាណដែលប្រើសម្រាប់ការរម្លាប់មេរោគក្នុងទឹកតាមផ្ទះនិងសហគមន៍ គឺមានសុវត្ថិភាព។ ការប្រើក្លរីនសម្រាប់រម្លាប់មេរោគក្នុងទឹកមានសុវត្ថិភាពជាងការប្រថុយប្រថាននឹងបញ្ហាសុខភាពដែលបង្កឡើងដោយមេរោគ។

## តើគួរប្រើក្លរីនប៉ុន្មាន ?

បរិមាណក្លរីនដែលចាំបាច់សម្រាប់ការរម្ងាប់មេរោគក្នុងទឹក គឺអាស្រ័យលើសភាពកខ្វក់របស់ទឹក(តើវាមានមេរោគប្រភេទណា និងមានប៉ុន្មាន)។ បើមានមេរោគកាន់តែច្រើននៅក្នុងទឹក នោះអ្នកត្រូវប្រើក្លរីនកាន់តែច្រើនដែរដើម្បីសម្លាប់វា។ ជាការសំខាន់គួរដាក់ក្លរីនឲ្យគ្រប់គ្រាន់ ដើម្បីឲ្យវាសល់នៅក្នុងទឹកខ្លះនៅពេលមេរោគងាប់ហើយ។ ក្លរីនសល់នឹងសម្លាប់មេរោគថ្មីៗដែលចូលទៅក្នុងទឹក។ បើមានក្លរីនសល់នៅក្នុងទឹក អ្នកអាចហិតឬភ្លក់ដឹងថាវាមានជាតិក្លរីនតែបន្តិចបន្តួចប៉ុណ្ណោះ។ នេះប្រាប់អ្នកឲ្យដឹងថា វាមានសុវត្ថិភាពសម្រាប់ផឹក។ ប្រសិនបើទឹកមានក្លរីនច្រើនពេក វានឹងមានក្លិនខ្លាំងនិងរសជាតិមិនល្អ។

ដើម្បីប្រើប្រាស់បរិមាណក្លរីនឲ្យបានត្រឹមត្រូវ អ្នកត្រូវដឹងថាសូលុយស្យុងក្លរីនរបស់អ្នក ខ្លាំងប៉ុនណា។ ក្លរីនមានច្រើនទម្រង់គឺ ឧស្ម័ន, ម្សៅសាវ៉ែល, high-test hypochlorite (HTH), និងទឹកសាវ៉ែលតាមផ្ទះ។ ដោយហេតុថាទឹកសាវ៉ែលតាមផ្ទះ គឺជាទម្រង់នៃក្លរីនដែលឃើញញឹកញាប់បំផុត ទើបសៀវភៅនេះបង្ហាញពីវិធីរម្ងាប់មេរោគក្នុងទឹកដោយប្រើទឹកសាវ៉ែលតាមផ្ទះ។

ទឹកសាវ៉ែលតាមផ្ទះអាចមានបរិមាណក្លរីនខុសៗគ្នា។ បរិមាណដែលឃើញញឹកញាប់បំផុតគឺ ៣,៥% និង៥%។ វិធីងាយបំផុតក្នុងការវាស់បរិមាណនៃទឹកសាវ៉ែលដែលត្រូវការ គឺដំបូងត្រូវធ្វើ "សូលុយស្យុងមេ" (ក្លរីនប្រហែល១%) សិន បន្ទាប់មកដាក់សូលុយស្យុងនេះចូលក្នុងទឹកដែលអ្នកចង់រម្ងាប់មេរោគ។ ដើម្បីលាយសូលុយស្យុងមេ ៖

- ចាក់ទឹកសាវ៉ែល១ពែង ចូលក្នុងដបស្អាតចំណុះ១លីត្រដែលនៅទទេរ។
- ចាក់ទឹកស្អាតបំពេញដប។
- ក្រឡុកដបរយៈពេល៣០វិនាទី។
- ទុកវាស្ងៀមរយៈពេល៣០នាទី។ សូលុយស្យុងមេរបស់អ្នក រួចរាល់ហើយ។

ប្រសិនបើមានកំទេចកំទីរឹងនៅក្នុងទឹក ក្លរីនក៏មិនអាចធ្វើការបានដែរ ដូច្នេះត្រូវច្រោះទឹកឬទុកទឹកឲ្យរងជាមុន។ ចាក់ទឹករងទៅក្នុងប្រដាប់ដាក់ទឹក(ធុង ឆ្នាំង ដប...) រួចលាយក្លរីន។

លាយសូលុយល្យុងមេក្នុងបរិមាណខាងលើនេះ រួចរង់ចាំយ៉ាងហោច៣០នាទីមុននឹងផឹក។ ប្រសិនបើទឹកល្អក់ អ្នកត្រូវបន្ថែមបរិមាណសូលុយស្យុងមេទ្វេរជាពីរ។

| ទឹក | "សូលុយស្យុងមេ" |
|---|---|
| សម្រាប់ទឹក ១លីត្រ | ៣តំណក់ |
| សម្រាប់ទឹក ៤លីត្រ | ១២តំណក់ |
| សម្រាប់ទឹក ២០លីត្រ | ១ស្លាបព្រាកាហ្វេ |
| សម្រាប់ទឹក ២០០លីត្រ | ១០ស្លាបព្រាកាហ្វេ |

**លាយសូលុយស្យុងមេចូលក្នុងទឹកថ្លាតាមបរិមាណខាងលើនេះ រួចរង់ចាំយ៉ាងតិច៣០នាទី មុននឹងផឹក។ ប្រសិនបើទឹកល្អក់ អ្នកចាំបាច់លាយសូលុយស្យុងមេក្នុងបរិមាណទ្វេរដង។**

# ទឹកសំណល់ : ជាបញ្ហា ឬជាធនធាន ?

ដោយហេតុថាបរិមាណទឹកក្នុងពិភពលោកនៅតែដដែល ដូច្នេះទឹកទាំងអស់ត្រូវបានប្រើឡើងវិញដដែលៗ។ ប៉ុន្តែទឹកដែលហូរលើដី និងទឹកដែលត្រូវបានប្រើសម្រាប់បោកគក់ កសិកម្ម អនាម័យ ឬឧស្សាហកម្ម ភាគច្រើនមានមេរោគនិងសារធាតុគីមីដែលធ្វើឲ្យវាគ្មានសុវត្ថិភាពសម្រាប់ផឹក ងូត និងបោកគក់។

ទឹកដែលមិនកខ្វក់ដោយសារធាតុគីមីពុលឬសំណល់របស់មនុស្សទេ អាចត្រូវបានប្រើប្រាស់ឡើងវិញ បន្ទាប់ ពីការបន្សុទ្ធសាមញ្ញៗ។ មធ្យោបាយដែលសមរម្យបំផុតសម្រាប់ប្រើក្នុងផ្ទះឬសហគមន៍របស់អ្នក អាស្រ័យលើបរិមាណទឹកសំណល់ដែលត្រូវបន្សុទ្ធ, តើអ្វីដែលធ្វើឲ្យទឹកកខ្វក់, តើវានឹងប្រើសម្រាប់អ្វី, តើពេលវេលាប៉ុន្មាន, ទីកន្លែង, និងពលកម្មដែលអ្នកមាន ក្នុងការបន្សុទ្ធទឹក។

## ដំណោះស្រាយលើទឹកប្រផេះ( ទឹកដែលប្រើប្រាស់រួច )

ទឹកប្រផេះ គឺជាទឹកដែលសល់ពីការប្រើប្រាស់ក្នុងការបោកគក់ និងកិច្ចការផ្ទះផ្សេងៗទៀត ប៉ុន្តែវាមិនមាន កាកសំណល់របស់មនុស្សទេ។ ដរាបណាអ្នកមិនបានប្រើប្រាស់សាប៊ូឬផលិតផលសម្អាតដែលមានសារធាតុពុល( មើលទំព័រ373 អំពីវិធីបង្កើតផលិតផលសម្អាតឲ្យមានសុវត្ថិភាពប្រសើរ ) នោះទឹកប្រផេះត្រូវការការ បន្សុទ្ធសាមញ្ញៗ ហើយអាចប្រើឡើងវិញនៅក្នុងសួនដំណាំ ឬមិនចាំបាច់បន្សុទ្ធអ្វីឡើយបើចាក់ចោលទៅដី។

**សំខាន់ :** ទឹកដែលប្រើប្រាស់រួច មិនអាចមានសុវត្ថិភាពសម្រាប់ផឹកទេ។

ប្រព័ន្ធទឹកប្រផេះមានច្រើនប្រភេទខុសៗគ្នា (មើលផ្នែកធនធាន)។ ប្រព័ន្ធទឹកប្រផេះគ្រប់ប្រភេទ មាន ប្រសិទ្ធភាពបំផុតនៅពេល :

- វាងាយនឹងសាងសង់ និងងាយថែទាំ។
- ខ្លាញ់, កំហាប់សារ៉ែល, សារធាតុរំលាយ, និងសារធាតុគីមីដទៃទៀត មិនបានចូលក្នុងទឹក។



### រៀបចំដីល្បាយខ្សាច់ដើម្បីច្រោះទឹកប្រផេះ

វិធីមួយក្នុងការកែច្នៃទឹកប្រផេះ គឺការធ្វើតាមវិធីធម្មជាតិដែលសម្អាតទឹកដោយការសាងសង់ដីល្បាយខ្សាច់។ ដីល្បាយខ្សាច់ កែច្នៃទឹកប្រផេះ ដោយការច្រោះទឹកឆ្លងកាត់ស្រទាប់រុក្ខជាតិ ដី និងថ្ម។ សារធាតុចិញ្ចឹមនៅក្នុង ទឹកសំណល់បានចិញ្ចឹមរុក្ខជាតិ, ហើយរុក្ខជាតិបានបន្ថែមអុកស៊ីសែនទៅក្នុងទឹក ដែលជួយសម្អាតទឹក។ ដីល្បាយខ្សាច់ក៏ :

- ផ្តល់ទឹកបញ្ចូលដំណាំ។
- ដាំរុក្ខជាតិ( ដូចជាឫស្សីឬត្រែង )ដែលអ្នកអាចប្រមូលផលសម្រាប់ប្រើក្នុងបំណងផ្សេងៗ។
- ប្តូរពីទឹកក្លិនអាក្រក់ទៅជាសួនដំណាំដ៏ស្រស់ស្អាត។

**សំខាន់ :** ដីល្បាយខ្សាច់មិនអាចកែច្នៃកាកសំណល់របស់មនុស្សទេ។

## ដើម្បីសាងសង់ដីល្បាយខ្សាច់

នៅពេលពិចារណាសាងសង់ដីល្បាយខ្សាច់ គួរពិចារណាលើចំណុចទាំងនេះ :

- តើអ្នកត្រូវការទំហំដីប៉ុនណា និងជម្រៅប៉ុន្មាន? បើមានទឹកកាន់តែច្រើនឆ្លងកាត់ប្រព័ន្ធដីល្បាយខ្សាច់ អ្នកត្រូវការជីកកាន់តែធំ និងជីកកាន់តែជ្រៅ ដើម្បីអាចច្រោះទឹកប្រផេះដោយសុវត្ថិភាព។ ប្រសិនបើទឹកហូរញាប់ពេក ដីល្បាយខ្សាច់មិនអាចសម្អាតវាបានល្អទេ។
- តើប្រភពទឹកខ្ពស់ជាងដីល្បាយខ្សាច់ដែរឬទេ? ទឹកត្រូវហូរឆ្លងកាត់ដីល្បាយខ្សាច់ ដូច្នេះវាត្រូវតែហូរមកពីប្រភពដែលស្ថិតនៅខាងលើ ឬហូរដោយការបង្ហូរ។
- តើទឹកដែលច្រោះរួចនឹងហូរទៅទីណា? តើទឹកនេះអាចយកទុកក្នុងអាងស្តុកទឹកបានឬទេ ឬហូរទៅសួនដំណាំដោយផ្ទាល់តែម្តង?

ដីល្បាយខ្សាច់អាចត្រូវបានសាងសង់នៅកន្លែងណាក៏បានឲ្យតែមានកន្លែងទំនេរគ្រប់គ្រាន់។ ប្រសិនបើមានកន្លែងទំនេរតូច អ្នកអាចសង់វានៅលើដី ក្នុងបាសាំងទឹក ដូចជាបាសាំងចំណុះ២០០លីត្រជាដើម។ ក្នុងតំបន់ដែលទឹកហូរចូលក្នុងដីបានល្អ ឬដែលមានទឹកក្រោមដីខ្ពស់ ចូរជីករណ្តៅមួយ រួចរៀបទ្រនាប់រណ្តៅដោយប្រើផ្លាស្ទិកក្រាស់ៗឬស៊ីម៉ង់។ ក្នុងតំបន់ដីតដ្ឋ អ្នកមិនចាំបាច់រៀបទ្រនាប់ទេ។

### ដើម្បីថែទាំដីល្បាយខ្សាច់ដែលសាងសង់រួច




**ដីល្បាយខ្សាច់ដែលជីកចូលក្នុងដី អាចកែច្នៃទឹកប្រផេះបានយ៉ាងច្រើន។**

ដីល្បាយខ្សាច់ទាំងឡាយមានតម្រូវការខុសៗគ្នា អាស្រ័យលើបរិមាណទឹក ប្រភេទដីនិងរុក្ខជាតិ និងលក្ខខណ្ឌដទៃទៀត។ ចូរសាកល្បងសាងសង់វាច្រើនដង ដើម្បីស្វែងរកវិធីល្អបំផុតក្នុងការធ្វើឲ្យដីល្បាយខ្សាច់ដែលសាងសង់រួច មានដំណើរការ។

- **ប្រសិនបើរុក្ខជាតិក្រៀមស្វិតឬងាប់** មានន័យថាទឹកមិនបានហូរឆ្លងកាត់គ្រប់គ្រាន់ទេ។ អ្នកអាចបន្ថែមប្រភពទឹកទៅប្រព័ន្ធដីល្បាយខ្សាច់នេះ អាចជីករណ្តៅតូចជាងនេះឬរាក់ជាងនេះ ឬបន្ថែមរុក្ខជាតិថ្មីៗ។
- **ប្រសិនបើទឹកមិនហូរ** ចូរសាកល្បងប្រើថ្មធំជាងនេះនិងបន្ថយខ្សាច់ ឬទម្លាក់បំពង់បង្ហូរទឹកចេញចុះក្រោមបន្តិច។